ក

មាតិកា

I. ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០១-០១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០១០៧/០០១ ស្តីពីការតម្លើងឋានន្តរស័ក្តិ ថ្នាក់ផ្កាយមាស ៤ ជូននាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០៦ រូប ៩៤៩

០១-០១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០១០៧/០០២ ស្តីពីការតែងតាំងឯកឧត្តម **ឆា ចារីនត់** ជាទីប្រឹក្សារាជរដ្ឋាភិបាល មានឋានៈស្មើ ទេសរដ្ឋមន្ត្រី ៩៥០

០១-០១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០១០៧/០០៥ ស្តីពីសញ្ញាសក្តិ និង ឯកសណ្ឋានមន្ត្រីក្របខ័ណ្ឌអភិបាល និងក្របខ័ណ្ឌឧបការី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ៩៥១

០៤-០១-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០១០៧/០០៦ ស្តីពីការតែងតាំងឯកឧត្តម **ជិន ចន្ថា** ជារដ្ឋលេខាធិការក្រសួងផែនការ ជំនួសឯកឧត្តម **តូ ឡាវី** ៩៦៧

II. រាជរដ្ឋាភិបាល

១. អនុក្រឹត្យ

២៦-០១-២០០៧ -អនុក្រឹត្យលេខ ០៨ អនក្រ.បក ស្តីពីរបបឧបត្ថម្ភចំពោះយោធិនពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ ៩៦៨

២៤-០១-២០០៧ -អនុក្រឹត្យលេខ ៦៦ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៩៧៧

២៤-០១-២០០៧ -អនុក្រឹត្យលេខ ៦៧ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៩៨០

២៦-០១-២០០៧ -អនុក្រឹត្យលេខ ៦៨ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៩៨២

២. សេចក្តីសំរេច

២៤-០១-២០០៧ -សេចក្តីសំរេចលេខ ០៣ សសរ ស្តីពីការបង្កើតគណៈកម្មការបច្ចេកទេស ដើម្បីសម្របសម្រួលក្នុងការសិក្សាបឋម និងត្រួតពិនិត្យគម្រោងវិនិយោគស្ថាបនាផ្លូវហាយវេថ្មី តភ្ជាប់ពីភ្នំពេញទៅក្រុងព្រះសីហនុ ឆ្លងកាត់ខេត្តតាកែវ និងខេត្តកំពត ៩៩៩

III. ការងារបណ្តាក្រសួង

១. ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៩-១២-២០០៦ -ប្រកាសលេខ ១៤០៤សហវ ស្តីពីការដាក់អោយអនុវត្តប្លង់គណនេយ្យទូទៅ នៃគណនេយ្យថវិកាស្រុក ខ័ណ្ឌ ១០០១

២៩-១២-២០០៦ -ប្រកាសលេខ ១៤០៩ សហវ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិកាខេត្ត ក្រុង និងស្រុក ខ័ណ្ឌ ១០៣៨

២_ឧស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

១៨-០១-២០០៧ -ប្រកាសលេខ ១០៩ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន វីនតាយ (ខេមបូឌា) ហ្គាមេន បង្កើតរោងចក្រ "កាត់ដេរ និងចាក់សម្លៀកបំពាក់ មួក ស្រោមជើង-ស្រោមដៃ និងកន្សែង" ដែលមានឈ្មោះថា "វីនតាយ (ខេមបូឌា) ហ្គាមេន" ១០៥៦

១៨-០១-២០០៧ -ប្រកាសលេខ ១១១ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន សាង មីន (ខេមបូឌា) ខូ អិលធីឌី បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា "សាង មីន (ខេមបូឌា) ខូ អិលធីឌី" ១០៥៨

១៨-០១-២០០៧ -ប្រកាសលេខ ១១២ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ប៊្លូសសាម សេនជូរី (ខេមបូឌា) បង្កើតរោងចក្រ "កាត់ដេរ និងចាក់សម្លៀកបំពាក់ មួក ស្រោមជើង-ស្រោមដៃ និងកន្សែង" ដែលមានឈ្មោះថា "ប៊្លូសសាម សេនជូរី (ខេមបូឌា)" ១០៦០

២៤-០១-២០០៧ -ប្រកាសលេខ ១២៤ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន រោងចក្របារីកម្ពុជា បង្កើតរោងចក្រ "ផលិតបារី" ដែលមានឈ្មោះថា រោងចក្រ បារី កម្ពុជា" ១០៦២

២៤-០១-២០០៧ -ប្រកាសលេខ ១២៥ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន វីវើរ ខប បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា "វីវើរ ខប" ១០៦៤

៣_ឧស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

១២-១២-២០០៦ -ប្រកាសលេខ ២៤១៣ អយក.ប្រក ស្តីពីការបង្កើតថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ១០៦៦

២២-១២-២០០៦ -ប្រកាសលេខ ២៩៧៨ អយក.ប្រក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃការប្រឡងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ១០៦៨

២២-១២-២០០៦ -ប្រកាសលេខ ២៩៧៩ អយក.ប្រក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃការប្រឡងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ ១០៧៣

៤_ឧស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៩-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦៦៣ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស្វាតេរីយ៉ា** ១០៧៨

១៩-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦៦៤ ពណ.នគក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិម ខេ អិល ធី & ខន ស្ត្រាក់សិន ខូ អិលធីឌី** ១០៨០

១៩-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦៦៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ិនធើណេសិនណល ឌីសាញ ឌីវើឡុបមេន** ១០៨២

១៩-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦៦៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឡាលីតខន គ្រុប** ១០៨៤

២០-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦៧១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **លីម៉ាក់ ខមភេនី អិលធីឌី** ១០៨៦

២០-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦៧៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្វ៊ីស ណាត-អ៊ីសធើន (ខេមបូឌា) រីសសស៍** ១០៨៨

២០-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦៧៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉ាល់ធី អេនជីនារីង គ្រុប** ១០៩០

២០-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦៧៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខូន តុខ ឃ្វារ អ៊ីមផត អិចផត** ១០៩២

២០-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦៨១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អានរិទ្ធ ត្រារាឌើរ** ១០៩៤

២០-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦៨៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មេកឃើរ ហ្វ៊ូច អេស៊ា ផេស៊ីហ្វិក អិលធីឌី** ១០៩៦

២០-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦៨៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉ាស្ទ័រ ដាយនើសធី លីមីធីត** ១០៩៧

២០-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦៨៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហៃទេ ថេកណូឡូជី (ខេមបូឌា)** ១០៩៩

២០-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦៨៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អូ អេស ស៊ី** ១១០១

២០-១០-២០០៦ -លិខិតបញ្ជាក់លេខ ២៦៨៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេ អាយ ជី ស៊ី** ១១០៣

ព្រះរាជក្រឹត្យ

នស/រកត/០១០៧/០០១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតម្លើងឋានន្តរស័ក្តិ ថ្នាក់នាយឧត្តមសេនីយ៍ផ្កាយមាស ៤ ជូននាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០៦ រូប ដូចមានរាយនាមខាងក្រោម :

១-ឧត្តមសេនីយ៍ឯក	**ឆា ទីរ៉ាត់**	អត្តលេខ ០០០០០៧
២-ឧត្តមសេនីយ៍ឯក	**ចាយ សាំងយុន**	អត្តលេខ ០០០០១០
៣-ឧត្តមសេនីយ៍ឯក	**ឈឹម ខិមយ៉ុន**	អត្តលេខ ០០០០២១
៤-ឧត្តមសេនីយ៍ឯក	**ម៉ុង សំផន**	អត្តលេខ ០០០០៧១
៥-ឧត្តមសេនីយ៍ឯក	**នាង ផាត**	អត្តលេខ ០០០០៨០
៦-ឧត្តមសេនីយ៍ឯក	**គន់ គីម**	អត្តលេខ ០០៤២៨២ ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

រ.ល.០៧០១.០០១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០៧

លេខ : ០៧៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

យុន ជិនភេន

ព្រះរាជក្រឹត្យ

នស/រកត/០១០៧/០០២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរជ្ជបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: ត្រូវបានតែងតាំងឯកឧត្តម ទា ចំរ៉ាត់ ជាទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ ទេសរដ្ឋមន្ត្រី ។

មាត្រា ២: សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៧៧.០៧០១.០០២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០៧

លេខ : ០៨ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មករា ឆ្នាំ២០០៧
អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០១០៧/០០៥

ស្ដីពី

សញ្ញាសក្តិ និង ឯកសណ្ឋានមន្ត្រីក្របខ័ណ្ឌអភិបាល និងក្របខ័ណ្ឌឧបការី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធានទី១ និង អនុប្រធានទី២ ព្រឹទ្ធសភា កាលពី ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៦ នាសម័យប្រជុំដំបូងនីតិកាលទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០៣/០០៧ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្ដីពីការប្រកាសឱ្យប្រើច្បាប់ ស្ដីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិបញ្ញត្តិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៦/១៣៧ ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៦ ស្ដីពីការតែងតាំងអគ្គលេខាធិការ អគ្គលេខាធិការរងនៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្ដីសំរេចលេខ ០៤១/១១០៥/ពស/សរ ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ស្ដីពីរចនាសម្ព័ន្ធគ្រប់គ្រងថ្មីរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចប្រធានព្រឹទ្ធសភា ។

គ្រាស់បន្ទាប់
ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

មាត្រា ១ :

ត្រូវបានបង្កើតសញ្ញាសក្តិ និងឯកសណ្ឋាន សម្រាប់សម្គាល់មន្ត្រីរាជការក្របខ័ណ្ឌអភិបាល និងក្របខ័ណ្ឌឧបការី ដែលបម្រើការងារនៅអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ។

មាត្រា ២ :

សញ្ញាសក្តិរួមមាន សក្តិចុងកអាវ សក្តិស្មា សក្តិចុងដៃអាវទាំងសងខាង និងសញ្ញាសម្គាល់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

ឯកសណ្ឋានរួមមាន ឯកសណ្ឋានផ្លូវការ និង ឯកសណ្ឋានប្រពៃណីជាតិ ។

សញ្ញាសក្តិ និង ឯកសណ្ឋាននេះ ប្រើប្រាស់នៅពេលចូលរួមពិធីបុណ្យប្រពៃណីជាតិ ពិធីបុណ្យជាតិ ពិធីផ្លូវការផ្សេងៗ ។

ជំពូកទី ២
អំពីសញ្ញាសក្តិ

មាត្រា ៣ :

សញ្ញាសក្តិនៃមន្ត្រីរាជការក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការី ត្រូវបានកំណត់ដូចតទៅ ÷

១ . ក្របខ័ណ្ឌមន្ត្រីអភិបាល

ក . សក្តិចុងកអាវ

សក្តិចុងកអាវមានផ្ទៃកម្ពីពណ៌ខៀវចាស់ រចនាតុបតែងដោយនៅផ្នែកខាងដើម និងខាងក្រោមតួសក្តិមានសញ្ញាសម្គាល់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ។ នៅផ្នែកកណ្តាលរហូតខាងចុងនៃតួសក្តិមានក្បាច់ភ្ញីវល្លិពណ៌មាសរចនាជាសន្លឹកផ្លែ និងផ្កា ដែលតំណាងនូវដំណាំរួមផ្សំនៅកម្ពុជា ហើយមានក្បាច់ក្របកឈូកពណ៌មាស នៅពីខាងក្រោមក្បាច់ភ្ញីវល្លិ និងសញ្ញាសម្គាល់ ។ នៅជាយនៃតួសក្តិចុងកអាវមានក្បាច់ជរជាយ រចនាជាខ្សែពួរវេញពណ៌មាសនៅជ្រុងខាងដើម ចំនួន០៣ ខ្សែ សម្រាប់សម្គាល់ឋានន្តរសក្តិ ឧត្តមអភិបាល ចំនួន០២ ខ្សែ សម្រាប់សម្គាល់ឋានន្តរសក្តិវរអភិបាល និង ចំនួន ០១ ខ្សែ សម្រាប់សម្គាល់ឋានន្តរសក្តិ អភិបាល ។ នៅពីផ្នែកខាងលើ និងផ្នែកខាងចុងនៃសញ្ញាសក្តិចុងកអាវមានក្បាច់ពួរវេញមួយខ្សែពណ៌មាស ។

ខ្នាតសក្តិចុងកអាវ ត្រូវបានកំណត់ដូចខាងក្រោមនេះ ÷

- មានរាងជាប្រលេឡូក្រាម
- បណ្តោយ ប្រវែង ០៨.០០ សង់ទីម៉ែត្រ
- ទទឹង ប្រវែង ០៣.៥០ សង់ទីម៉ែត្រ

ខ . សក្តិស្មា

សក្តិស្មាមានផ្ទៃកម្ទីពណ៌ខៀវចាស់ រចនាតុបតែងដោយក្បាច់ភ្ញីវល្លិពណ៌មាសចំកណ្តាល ដែលមានជាសន្ទឹក ផ្លែ និងផ្កា តំណាងនូវជំលាំរួមផ្សំនៅកម្ពុជា ។ នៅពីខាងលើក្បាច់ភ្ញីវល្លិមានសញ្ញាសម្គាល់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ហើយនៅពីខាងលើសញ្ញាសម្គាល់នេះ មានឡេវរូបព្រះសង្ហារពណ៌មាសមួយដែលមានអង្កត់ផ្ចិតប្រវែង ០១,៨០ សង់ទីម៉ែត្រ ។ ឡេវ សញ្ញាសម្គាល់ និងក្បាច់ភ្ញីវល្លិហ៊ុំព័ទ្ធជុំវិញដោយក្បាច់ត្របកឈូកពណ៌មាស ។ នៅ ជាយនៃតួសក្តិស្មាមានក្បាច់ជរជាយ រចនាជាខ្សែពួរវេញពណ៌មាស ចំនួន ០៣ ខ្សែ សម្រាប់សម្គាល់ឋានន្តរសក្តិឧត្តមអភិបាល ចំនួន ០២ខ្សែ សម្រាប់សម្គាល់ឋានន្តរសក្តិវរអភិបាល និង ចំនួន ០១ ខ្សែ សម្រាប់សម្គាល់ ឋានន្តរសក្តិអភិបាល ។

ខ្នាតសក្តិស្មាត្រូវបានកំណត់ដូចខាងក្រោមនេះ ៖

- បាតក្រោម ប្រវែង ០៦.០០ សង់ទីម៉ែត្រ
- ទទឹងមុខកាត់ផ្នែកខាងលើ ប្រវែង ០៤.៥០ សង់ទីម៉ែត្រ មានរាងកោងជាមុំទាល
- បណ្តោយពីលើដល់បាតក្រោមប្រវែង ១៣.០០ សង់ទីម៉ែត្រ ។

គ . សក្តិចុងដៃអាវ

សក្តិចុងដៃអាវមានផ្ទៃកម្ទីពណ៌ខៀវចាស់ រចនាតុបតែងដោយក្បាច់ភ្ញីវល្លិពណ៌មាស ដែលមានជាសន្ទឹក ផ្លែ និង ផ្កា តំណាងនូវជំលាំរួមផ្សំនៅកម្ពុជា មានសញ្ញាសម្គាល់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅចំកណ្តាលនៃក្បាច់ភ្ញីវល្លិ ហើយមានក្បាច់ត្របកឈូកពណ៌មាស ហ៊ុំព័ទ្ធក្បាច់ភ្ញីវល្លិនៅជាយផ្នែកខាងលើ និងផ្នែកចំហៀងទាំងសងខាង។ នៅជាយនៃតួសក្តិចុងដៃអាវមានក្បាច់ជរជាយ រចនាជាខ្សែពួរវេញពណ៌មាស ហ៊ុំព័ទ្ធជាបីជ្រុង គឺនៅផ្នែកខាងលើ និងផ្នែកចំហៀងទាំងសងខាង ចំនួន០៣ខ្សែ សម្រាប់សម្គាល់ ឋានន្តរសក្តិឧត្តមអភិបាល ចំនួន០២ ខ្សែ , សម្រាប់សម្គាល់ឋានន្តរសក្តិវរអភិបាល និងចំនួន ០១ ខ្សែ សម្រាប់សម្គាល់ ឋានន្តរសក្តិអភិបាល ។ នៅបាតក្រោមបង្អស់នៃសញ្ញាសក្តិចុងដៃអាវ មានក្បាច់ពួរវេញមួយខ្សែពណ៌មាស ។

ខ្នាតសក្តិចុងដៃអាវត្រូវបានកំណត់ដូចខាងក្រោមនេះ ៖

- មានរាងបួនជ្រុងទ្រវែង
- បណ្តោយ ប្រវែង ៣២.០០ សង់ទីម៉ែត្រ
- ទទឹង ប្រវែង ០៨.០០ សង់ទីម៉ែត្រ

រូបគំនូរសក្តិចុងកអាវ សក្តិស្មា និងសក្តិចុងដៃអាវទាំងសងខាង សម្រាប់មន្ត្រី ៖

- ឋានន្តរសក្តិឧត្តមអភិបាល មានគំរូដូចក្នុងឧបសម្ព័ន្ធទី ១
- ឋានន្តរសក្តិវរអភិបាល មានគំរូដូចក្នុងឧបសម្ព័ន្ធទី ២
- ឋានន្តរសក្តិអភិបាល មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៣ នៃព្រះរាជក្រឹត្យនេះ ។

ឃ . សញ្ញាសម្គាល់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

សញ្ញាសម្គាល់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សម្រាប់រចនាលើសក្តិចុងកអាវ សក្តិស្មា សក្តិចុងដៃអាវ និង សម្រាប់ជាសក្តិកន្ធាស់ក្លាស់លើអាវបុរស នារី ឬ លើក្រមាពាននារី សម្រាប់មន្ត្រីរាជការក្របខ័ណ្ឌអភិបាល មាន រាងមូលទ្រវែង មានកម្ពស់ ០៦.០០ សង់ទីម៉ែត្រ ទទឹង ០៤.៥០ សង់ទីម៉ែត្រ ។

នៅផ្នែកខាងលើនៃសញ្ញាសម្គាល់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានរចនាដោយជើងពានពីរជាន់ទ្រចតុកោណ កែងមួយ ពណ៌មាស ដែលមានចារឹកអក្សរព្រឹទ្ធសភា និងសៀវភៅរដ្ឋធម្មនុញ្ញមានរូបអង្គរពីខាងក្រោយ មានកាំរស្មី ចំនួន ២៤ មានភ្ញីស្លឹកឈើព័ទ្ធឡើងលើជាស្នែងក្របី ស្ថិតនៅខាងក្រោមជើងពាន ។ នៅផ្នែកកណ្តាល មាននាគ មួយគូ ពណ៌មាស ពាំកួរស្រូវ ចំនួន ០៥ គ្រាប់ក្នុងម្ខាង១ ។ នៅចំពាក់កណ្តាលនៃគូនាគមួយគូ មានរចនាលំអដោយ ក្បាច់ផ្កាចន្ទន៍ពណ៌មាស ។ នៅពីខាងក្រោយសញ្ញាសម្គាល់ មានផ្ទៃពណ៌ខៀវចាស់ ។ នៅពីក្រោមរូបនាគមួយគូ មាន រចនាជាបន្ទះសម្រាប់សរសេរអក្សរពណ៌ក្រហម និងនៅតាមជរជាយមានពណ៌ខៀវ ព័ទ្ធឡើងលើជាស្នែងក្របីភ្ជាប់ទៅ នឹងកួរស្រូវ ដែលក្នុងនោះមានចារឹកអក្សរខ្មែរថា "**អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**" ជាពណ៌មាស ។

២ . ក្របខ័ណ្ឌមន្ត្រីឧបការី

សញ្ញាសក្តិ (សក្តិចុងកអាវ សក្តិស្មា សក្តិចុងដៃអាវទាំងសងខាង និងសញ្ញាសម្គាល់អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា) សម្រាប់មន្ត្រីក្របខ័ណ្ឌឧបការី មានសណ្ឋាន រូបភាព និងមានការបែងចែកទៅតាមឋានន្តរសក្តិ ដូចសញ្ញា សក្តិមន្ត្រីក្របខ័ណ្ឌអភិបាលដែរ ប៉ុន្តែខុសគ្នាត្រង់សញ្ញាសក្តិ សម្រាប់មន្ត្រីក្របខ័ណ្ឌឧបការី មានពណ៌ប្រាក់។ ដោយ ឡែកសញ្ញាសម្គាល់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដែលរចនាលើសក្តិចុងកអាវ សក្តិស្មា និងសក្តិចុងដៃអាវ មាន ពណ៌មាស។

រូបគំនូរសក្តិចុងកអាវ សក្តិស្មា និងសក្តិចុងដៃអាវទាំងសងខាង សម្រាប់មន្ត្រី ÷

- ឋានន្តរសក្តិនាយឧបការី មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៤
- ឋានន្តរសក្តិឧបការីដើមខ្សែ មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៥
- ឋានន្តរសក្តិឧបការី មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៦នៃព្រះរាជក្រឹត្យនេះ ។

រូបគំនូរសញ្ញាសម្គាល់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សម្រាប់មន្ត្រីរាជការក្របខ័ណ្ឌអភិបាល និងក្របខ័ណ្ឌ ឧបការី មានគំរូដូចក្នុងឧបសម្ព័ន្ធ ទី៧ នៃព្រះរាជក្រឹត្យនេះ ។

៣. សញ្ញាសក្តិសម្រាប់មន្ត្រីរាជការជានារី

សក្តិចុងកអាវ សក្តិស្មា និងសក្តិចុងដៃអាវ សម្រាប់មន្ត្រីរាជការក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការី ជានារី គឺដូចគ្នាគ្រប់ចំណុច និងគ្រប់ឋានន្តរសក្តិទាំងអស់របស់បុរស ប៉ុន្តែខុសគ្នាតែពីទំហំប៉ុណ្ណោះគឺ ÷

- សក្តិចុងកអាវ : អាចមានទទឹងពី ០៣ ទៅ ០៣.៥០ សង់ទីម៉ែត្រ អាស្រ័យលើមាឌនារី
- សក្តិស្មា : អាចមានទំហំ ៨០% ឬ ៨៥% ឬ ៩០% នៃសក្តិស្មារបស់បុរស អាស្រ័យលើមាឌរបស់នារី
- សក្តិចុងដៃអាវ : អាចមានទំហំទទឹងស្មើនឹង ៧០% ទៅ ៧៥% នៃទំហំសក្តិចុងដៃអាវរបស់បុរស អាស្រ័យ លើមាឌរបស់នារី ។

ជំពូកទី ៣

អំពីឯកសណ្ឋាន និង ការប្រើប្រាស់

មាត្រា ៤ :

ឯកសណ្ឋានសម្រាប់សម្គាល់មន្ត្រីរាជការក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការី ដែលបម្រើការងារនៅអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ត្រូវបានកំណត់ដូចខាងក្រោម ÷

១ . ឯកសណ្ឋានផ្លូវការ

ក . ចំពោះបុរស

- អាវកុដពណ៌ស កត្រង់ កាត់រាងអាវធំគ្មានផែកខ្នង ។ ចុងកអាវទាំងសងខាង មានសក្តិចុងកអាវតាមឋានន្តរសក្តិ មានបន្ទះលើស្មាសម្រាប់ដាក់សក្តិមួយគូ ។ ដៃអាវវែង ហើយនៅចុងដៃអាវមានសក្តិចុងដៃអាវតាមឋានន្តរសក្តិ ។ មានហោប៉ៅចោះបង្កប់ចំនួន ៤ នៅខាងលើពីរ និងនៅខាងក្រោមពីរ ដែលមានគម្របរាងស្លឹកពោធិស្រួចចំកណ្តាលចោះរន្ធឡេវសម្រាប់បិទ ហើយនៅលើគម្របហោប៉ៅទាំងបួននោះមានឡេវរូបព្រះសង្ការពណ៌មាស ឬ ប្រាក់ទៅតាមក្របខ័ណ្ឌ (ពណ៌មាសសម្រាប់មន្ត្រីរាជការក្របខ័ណ្ឌអភិបាល ពណ៌ប្រាក់ សម្រាប់មន្ត្រីរាជការ ក្របខ័ណ្ឌឧបការី) ដែលមានអង្កត់ផ្ចិតប្រវែង ០១,៨០ សង់ទីម៉ែត្រ ។ អាវកុដពណ៌សនេះ បិទឡេវរូបព្រះសង្ការ ពណ៌មាស ឬពណ៌ប្រាក់ទៅតាមក្របខ័ណ្ឌចំនួន ០៧ ដែលឡេវនីមួយៗ មានអង្កត់ផ្ចិតប្រវែង ០២,៥០ សង់ទីម៉ែត្រ ។

- ខោជើងវែងពណ៌ស គចង្កេះភ្ជឹបកក្រោយខាងឆ្វេង ០២ ខាងស្តាំ ០២ ហោប៉ៅចំហៀងនៅសងខាង ហោប៉ៅចោះក្រោយ ០១ នៅខាងស្តាំ ។

- ស្បែកជើងឃ្លុបកខ្ចី ពណ៌ខ្មៅចងខ្សែ និង ស្រោមជើងពណ៌ខ្មៅ ។

ខ . ចំពោះនារី

- អាវជីបរាង ពណ៌ស ដោយប្រើសាច់ក្រណាត់ដូចឈុតអាវបុរសដែរ កត្រង់ គ្មានផែកខ្នង បិទឡេវមុខមានដាក់ឡេវរូបព្រះសង្ការពណ៌មាស ឬ ប្រាក់ទៅតាមក្របខ័ណ្ឌ ចំនួន ០៥ មានអង្កត់ផ្ចិតប្រវែង ០២,៥០សង់ទីម៉ែត្រ។ ចុងកអាវទាំងសងខាងមានសក្តិចុងកអាវតាមឋានន្តរសក្តិ មានបន្ទះសក្តិលើស្មាសម្រាប់ដាក់សក្តិមួយគូ មានហោប៉ៅចោះ ចំនួន ០៤ នៅខាងលើពីរ និងនៅខាងក្រោមពីរ ដោយមានគម្របរាងស្លឹកពោធិ៍ស្រួចចំកណ្តាលចោះរន្ធឡេវសំរាប់បិទ។ ដៃអាវវែង ត្រឹមភ្នែកគោលដៃ ចុងដៃអាវមានសក្តិតាមឋានន្តរសក្តិ ។

- សំពត់សំឡុយអំពីជាមួងពណ៌ខៀវ មានសម្រុងលើភ្នែកគោលនៃស្មងជើងប្រវែងពី ១០ ទៅ ១៥ សង់ទីម៉ែត្រ អាស្រ័យទៅតាមមាឌ និង កម្ពស់។

- ស្បែកជើងអេស្កាប៉ាង ឃ្លុបមុខ ឃ្លុបក្រោយ គ្មានចងខ្សែ មានកែង ពណ៌សសម្រាប់ពេលព្រឹកដល់ថ្ងៃត្រង់ និងពណ៌ខ្មៅសម្រាប់ពេលល្ងាច ។

រូបគំនូរឯកសណ្ឋានផ្លូវការសម្រាប់បុរស និង នារី មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៨ នៃព្រះរាជក្រឹត្យនេះ ។

២ . ឯកសណ្ឋានប្រពៃណីជាតិ

ក . ចំពោះបុរស

- អាវកុដពណ៌ស កត្រង់ កាត់រាងអាវចំគ្មានផែកខ្នង ។ ចុងកអាវទាំងសងខាង មានសក្តិចុងកអាវ មានបន្ទះលើស្មាសម្រាប់ដាក់សក្តិមួយគូ ។ ដៃអាវវែង ហើយនៅចុងដៃអាវមានសក្តិចុងដៃអាវ ។ មានហោប៉ៅចោះបង្កប់ចំនួន ០៤ នៅខាងលើពីរ និងនៅខាងក្រោមពីរ ដែលមានគម្របរាងស្លឹកពោធិស្រួចចំកណ្តាល ចោះរន្ធឡេវសម្រាប់បិទ ហើយនៅលើគម្របហោប៉ៅទាំងបួននោះមានឡេវរូបព្រះសង្ហារពណ៌មាស ដែលមានអង្កត់ផ្ចិតប្រវែង ០១.៨០ សង់ទីម៉ែត្រ ។ អាវកុដពណ៌សនេះ បិទឡេវរូបព្រះសង្ហារពណ៌មាសចំនួន ០៧ ដែលឡេវ នីមួយៗមានអង្កត់ផ្ចិតប្រវែង ០២.៥០ សង់ទីម៉ែត្រ ។

- សំពត់ផាមួងចងក្បិន ពណ៌តាមថ្ងៃ ។

- ស្បែកជើងឃ្លុបពណ៌ខ្មៅ កខ្លី មានចងខ្សែ និងស្រោមជើងពណ៌ខ្មៅដល់ក្បាលជង្គង់ ។

ខ . ចំពោះនារី

- អាវជីបរាង ពណ៌ "ស" ដៃវែងត្រឹមភ្នែកគោលដៃ កវៀលមូលខាងមុខធ្លាក់ចុះពីក្បាលឆ្អឹងដងកាំបិតប្រវែង ០១.៥០ សង់ទីម៉ែត្រ និងត្រង់ស្មាឃ្លាតពីគល់កប្រមាណ ០២.៥០ សង់ទីម៉ែត្រ ទៅ ០៣.០០ សង់ទីម៉ែត្រ អាស្រ័យទៅតាមមាឌរបស់នារី ។ អាវនេះ គ្មានសក្តិស្មា និងសក្តិចុងកអាវ ប៉ុន្តែមានសក្តិចុងដៃអាវទាំងសងខាង តាមក្របខ័ណ្ឌ និង ឋានន្តរសក្តិ ។

- ពានាក្រមាពណ៌តាមសំពត់ ។ សាច់ក្រមា ដែលធ្វើអំពីសូត្រ មានផ្ទៃពណ៌ខ្ចីជាងសំពត់ ឬ ពានាក្រមាពណ៌ស៊ីនួន ឬ តាមពិធីការកំណត់ ហើយនៅលើក្រមាពានាផ្នែកខាងឆ្វេងនៃដើមទ្រូង ត្រូវក្ចាស់ "**សញ្ញាសម្គាល់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**" សម្រាប់សម្គាល់មន្ត្រីរាជការក្របខ័ណ្ឌអភិបាល ។

- សំពត់ផាមួងចងក្បិនពណ៌តាមថ្ងៃ

- ស្បែកជើងឃ្លុបមុខ ឃ្លុបក្រោយ គ្មានចងខ្សែ មានកែង ពណ៌សសម្រាប់ពេលព្រឹកដល់ថ្ងៃត្រង់ និងពណ៌ខ្មៅសម្រាប់ពេលល្ងាច ។

- កាបូបយួរដៃពណ៌ស ឬ ពណ៌ខ្មៅ(មិនឱ្យស្ពាយទេ) ស្របតាមការប្រើស្បែកជើងពណ៌ស ឬ ពណ៌ខ្មៅ ។

រូបគំនូរឯកសណ្ឋានប្រពៃណីជាតិសម្រាប់បុរស និង នារី មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៩ នៃព្រះរាជក្រឹត្យនេះ ។

<u>មាត្រា ៥</u> :

ការប្រើប្រាស់ឯកសណ្ឋានសម្រាប់មន្ត្រីរាជការក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការី ត្រូវបានកំណត់ដូចខាងក្រោម ÷

- ឯកសណ្ឋានផ្លូវការ សម្រាប់ប្រើប្រាស់ក្នុងឱកាសទទួលគ្រឿងឥស្សរិយយស ទិវាបុណ្យជាតិ និងពិធីផ្លូវការផ្សេងៗទៀតរបស់រដ្ឋ ឬ តាមការកំណត់របស់ថ្នាក់ដឹកនាំស្ថាប័ន ។

- ឯកសណ្ឋានប្រពៃណីជាតិសម្រាប់ប្រើប្រាស់ក្នុងទិវាបុណ្យប្រពៃណីជាតិ និង សាសនា ដែលប្រារព្ធធ្វើឡើងនៅក្នុងព្រះបរមរាជវាំង ឬ ក្នុងវត្តអារាម ឬ ទីកន្លែងផ្សេងៗ ត្រូវបានកំណត់ឱ្យប្រើសំរាប់តែមន្ត្រីរាជការក្របខ័ណ្ឌអភិបាល ដែលមានឋានន្តរសក្តិឧត្តមអភិបាល ។

ឯកសណ្ឋានទាំងពីរប្រភេទខាងលើនេះ ក៏ត្រូវស្លៀកពាក់ទៅតាមការកំណត់ក្នុងសេចក្តីអញ្ជើញជាផ្លូវការរបស់គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ និង អន្តរជាតិ ឬ ក្រសួងព្រះបរមរាជវាំង ។

ជំពូកទី ៤
របបកំណត់សញ្ញាសក្តិ និងឯកសណ្ឋាន

មាត្រា ៦:

សញ្ញាសក្តិ ឯកសណ្ឋានផ្លូវការ ឯកសណ្ឋានប្រពៃណីជាតិ និងសម្ភារៈផ្សេងៗទៀត ដូចបានកំណត់ក្នុងព្រះរាជក្រឹត្យនេះ ត្រូវបានផ្តល់ជូនដល់មន្ត្រីរាជការក្របខ័ណ្ឌអភិបាល និងក្របខ័ណ្ឌឧបការី មួយសម្រាប់ក្នុងម្នាក់ៗ សម្រាប់ប្រើប្រាស់រយៈពេល ០៦ ឆ្នាំ ។

ការចំណាយលើសញ្ញាសក្តិ ឯកសណ្ឋានគ្រប់ប្រភេទ និងសម្ភារៈផ្សេងៗទៀតដូចបានកំណត់ក្នុងព្រះរាជក្រឹត្យនេះ ជាបន្ទុកថវិការដ្ឋ ។

ជំពូកទី ៥
អវសានប្បញ្ញត្តិ

មាត្រា ៧:

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៨:

ប្រធានព្រឹទ្ធសភា នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និង អគ្គលេខាធិការព្រឹទ្ធសភា ត្រូវទទួលអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៩៧.០៧០១.០០៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ. ថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០៧

លេខ : ៣២ ច.ល
[illegible]ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ មករា ឆ្នាំ២០០៧
[illegible]រាជរដ្ឋាភិបាល
[illegible] ជិនកេន

សញ្ញាសក្តិមន្ត្រី ឋានន្តរសក្តិ ឧត្តមអភិបាល (ពណ៌មាស)

ឧបសម្ព័ន្ធទី១ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០១០៧/០០៥
ចុះថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៧ស្តីពីសញ្ញាសក្តិ និងឯកសណ្ឋានមន្ត្រី
នៃក្របខ័ណ្ឌអភិបាល និងក្របខ័ណ្ឌឧបការី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា



សក្តិចុងកអាវ



សក្តិស្មា



សក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី២ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០១០៧/០០៥ ចុះថ្ងៃទី ០១ ខែមករា ឆ្នាំ ២០០៧ស្តីពីសញ្ញាសក្តិ និងឯកសណ្ឋានមន្ត្រី នៃក្របខ័ណ្ឌអភិបាល និងក្របខ័ណ្ឌឧបការី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

សញ្ញាសក្តិមន្ត្រី ឋានន្តរសក្តិ ទីរអភិបាល (ពណ៌មាស)



សក្តិចុងកអាវ



សក្តិស្មា



សក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី៣ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០១០៧/០០៥
ចុះថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៧ស្តីពីសញ្ញាសក្តិ និងឯកសណ្ឋានមន្ត្រី
នៃក្របខ័ណ្ឌអភិបាល និងក្របខ័ណ្ឌឧបការី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

សញ្ញាសក្តិមន្ត្រី ឋានន្តរសក្តិ អភិបាល (ពណ៌មាស)



សក្តិចុងករអាវ



សក្តិស្មា



សក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី៤ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០១០៧/០០៥
ចុះថ្ងៃទី ០១ ខែមករា ឆ្នាំ ២០០៧ស្តីពីសញ្ញាសក្តិ និងឯកសណ្ឋានមន្ត្រី
នៃក្របខ័ណ្ឌអភិបាល និងក្របខ័ណ្ឌឧបការី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

សញ្ញាសក្តិមន្ត្រី ឋានន្តរសក្តិ នាយឧបការី (ពណ៌ប្រាក់)



សក្តិចុងកអាវ



សក្តិស្មា



សក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី៩ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០១០៧/០០៥
ចុះថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៧ស្តីពីសញ្ញាសក្តិ និងឯកសណ្ឋានមន្ត្រី
នៃក្របខ័ណ្ឌអភិបាល និងក្របខ័ណ្ឌឧបការី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

សញ្ញាសក្តិមន្ត្រី ឋានន្តរសក្តិ ឧបការីដើមខ្សែ (ពណ៌ប្រាក់)



សក្តិស្មា

សក្តិចុងកអាវ



សក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី៦ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០១០៧/០០៥
ចុះថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៧ស្តីពីសញ្ញាសក្តិ និងឯកសណ្ឋានមន្ត្រី
នៃក្របខ័ណ្ឌអភិបាល និងក្របខ័ណ្ឌឧបការី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

សញ្ញាសក្តិមន្ត្រី ឋានន្តរសក្តិ ឧបការី (ពណ៌ប្រាក់)

សក្តិចុងកអាវ



សក្តិស្មា



សក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី៧ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០១០៧/០០៥
ចុះថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៧ស្តីពីសញ្ញាសក្តិ និងឯកសណ្ឋានមន្ត្រី
នៃក្រុមខ័ណ្ឌអភិបាល និងក្រុមខ័ណ្ឌឧបការី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

សញ្ញាសម្គាល់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា



សម្រាប់ក្រុមខ័ណ្ឌអភិបាល (ពណ៌មាស)

សម្រាប់ក្រុមខ័ណ្ឌឧបការី (ពណ៌ប្រាក់)

ឯកសណ្ឋានផ្លូវការ

ឧបសម្ព័ន្ធទី៨ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០១០៧/០០៥
ចុះថ្ងៃទី ០១ ខែមករា ឆ្នាំ ២០០៧ស្តីពីសញ្ញាសក្តិ និងឯកសណ្ឋានមន្ត្រី
នៃក្របខ័ណ្ឌអភិបាល និងក្របខ័ណ្ឌឧបការី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា



ឯកសណ្ឋានប្រពៃណីជាតិ

ឧបសម្ព័ន្ធទី៩ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០១០៧/០០៥
ចុះថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៧ស្តីពីសញ្ញាសក្តិ និងឯកសណ្ឋានមន្ត្រី
នៃក្របខ័ណ្ឌអភិបាល និងក្របខ័ណ្ឌឧបការី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា



ព្រះរាជក្រឹត្យ

នស/រកត/០១០៧/០០៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានទ្រង់យល់សម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី ៣ នាថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីលទ្ធផលនៃការបោះឆ្នោតទុកចិត្តលើការកែសម្រួលសមាភាពរាជរដ្ឋាភិបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១: ត្រូវបានតែងតាំងឯកឧត្តម ផន ចន្ថា ជារដ្ឋលេខាធិការក្រសួងផែនការ ជំនួសឯកឧត្តម ឡូ ម្ការី ។

មាត្រា២: សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៧០១.០០៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ មករា ឆ្នាំ ២០០៧

លេខ: ៤៨ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧
[illegible]រាជរដ្ឋាភិបាល

ស៊ុន ចិនកេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

របបឧបត្ថម្ភចំពោះយោធិនពលី មរណៈ មនុស្សស្លាប់ បាត់ខ្លួន និងពិការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ ០៧ /នស/៩៤ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤០៦/០០៨ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃ កងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៧

សម្រេច

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះមានគោលដៅកំណត់របបឧបត្ថម្ភចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ដែលបានពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ ។

មាត្រា ២.-

វាក្យស័ព្ទដែលប្រើក្នុងអនុក្រឹត្យនេះ មានន័យដូចតទៅ ÷

- យោធិនពលី សំដៅដល់យោធិន ដែលបានបាត់បង់ជីវិត នៅពេលដែលបានទទួលបញ្ជាទៅប្រយុទ្ធ បម្រើការប្រយុទ្ធ ហ្វឹកហាត់ជំនាញគ្រោះថ្នាក់បំផុត ធ្វើការពិសោធន៍ដ៏មានគ្រោះថ្នាក់ និងដោយសារគ្រោះថ្នាក់ធម្មជាតិ

- យោធិនមរណៈ សំដៅដល់យោធិន ដែលបានទទួលបញ្ជាទៅបំពេញការងារក្នុងតំបន់ធម្មតា ហើយត្រូវទទួលគ្រោះថ្នាក់បាត់បង់ជីវិត ដោយសារការងារទាំងនោះ ឬដោយសារជំងឺ

- យោធិនបង្កស្លាប់ សំដៅដល់យោធិនដែលបានបាត់បង់ជីវិតដោយធ្វើអត្តឃាត ឬដោយសារបង្កគ្រោះថ្នាក់ ដល់បាត់បង់ជីវិតដោយផ្ទាល់ ឬប្រយោល មកពីល្មើសច្បាប់ វិន័យ និងបទបញ្ជា

- យោធិនបាត់ខ្លួន សំដៅដល់យោធិន ដែលបានទទួលបញ្ជាឱ្យទៅប្រយុទ្ធ បម្រើការប្រយុទ្ធ ហ្វឹកហាត់ជំនាញឯកទេស និងធ្វើការពិសោធន៍ប្រកបដោយគ្រោះថ្នាក់ ហើយត្រូវបាត់ខ្លួនដែលពុំអាចសន្និដ្ឋានបានថាស្លាប់ ឬ រស់ រត់ចោលជួរ រត់ចូលខ្មាំង ឬ ត្រូវខ្មាំងចាប់

- យោធិនពិការ សំដៅដល់យោធិនដែលបាត់បង់សរីរាង្គណាមួយ ឬច្រើននៅលើរាងកាយដោយបានចូលរួមប្រយុទ្ធ បម្រើការប្រយុទ្ធ ហ្វឹកហាត់ជំនាញគ្រោះថ្នាក់ ធ្វើការពិសោធន៍ដ៏មានគ្រោះថ្នាក់ និងដោយសារគ្រោះថ្នាក់ធម្មជាតិ ឬបំពេញការងារធម្មតា ។

ជំពូកទី ២

ប្រភេទយោធិនពិការ

មាត្រា ៣.-

យោធិនពិការ មាន២ ប្រភេទ គឺ ÷

- យោធិនពិការប្រភេទ "ក" ជាយោធិនមានជំងឺរបួសក្លាយជា យោធិនពិការដោយចូលរួមប្រយុទ្ធ បម្រើការប្រយុទ្ធ ហ្វឹកហាត់ជំនាញគ្រោះថ្នាក់ ធ្វើការពិសោធន៍ដ៏មានគ្រោះថ្នាក់ និងដោយសារគ្រោះថ្នាក់ធម្មជាតិ ត្រូវបានចែកចេញជា ៤ ថ្នាក់ ÷

-ថ្នាក់ទី ១ មានកម្រិតបាត់បង់សមត្ថភាពការងារលើសពី ៨០ (ប៉ែតសិប) ភាគរយ

-ថ្នាក់ទី ២ មានកម្រិតបាត់បង់សមត្ថភាពការងារលើសពី ៦០ (ហុកសិប) ភាគរយ

-ថ្នាក់ទី ៣ មានកម្រិតបាត់បង់សមត្ថភាពការងារលើសពី ៤០ (សែសិប) ភាគរយ

-ថ្នាក់ទី ៤ មានកម្រិតបាត់បង់សមត្ថភាពការងារលើសពី ២០ (ម្ភៃ) ភាគរយ

- យោធិនពិការប្រភេទ "ខ" ជាយោធិន ដែលមានជំងឺរបួស ក្លាយទៅជាយោធិនពិការ ដោយទទួលបញ្ជាទៅបំពេញការងារក្នុងតំបន់ធម្មតា ហើយត្រូវទទួលគ្រោះថ្នាក់ ត្រូវបានចែកចេញជា ៣ ថ្នាក់ ÷

-ថ្នាក់ទី ១ មានកម្រិតបាត់បង់សមត្ថភាពការងារលើសពី ៨០ (ប៉ែតសិប) ភាគរយ

-ថ្នាក់ទី ២ មានកម្រិតបាត់បង់សមត្ថភាពការងារលើសពី ៦០ (ហុកសិប) ភាគរយ

-ថ្នាក់ទី ៣ មានកម្រិតបាត់បង់សមត្ថភាពការងារលើសពី ៤០ (សែសិប) ភាគរយ ។

មាត្រា ៤.-

យោធិនពិការប្រភេទ "ក" ដែលទទួលមរណៈភាព មានលិខិតបញ្ជាក់មរណៈភាព ត្រូវបានទទួលស្គាល់ជាយោធិនពលី ។

យោធិនពិការប្រភេទ "ក" ដែលរងរបួសបន្ថែមទៀត ដោយសារការចូលរួមប្រយុទ្ធ ឬបម្រើការប្រយុទ្ធ ឬបំពេញការងារធម្មតា ត្រូវបានពិនិត្យវាយតម្លៃថ្នាក់ពិការឡើងវិញ ។

មាត្រា ៥.-

យោធិនពិការប្រភេទ "ខ" ដែលទទួលមរណៈភាព មានលិខិតបញ្ជាក់មរណៈភាព ត្រូវបានទទួលស្គាល់ជាយោធិនមរណៈ ។

យោធិនពិការប្រភេទ "ខ" ដែលរងរបួសបន្ថែមទៀត ដោយសារការចូលរួមប្រយុទ្ធ ឬបម្រើការប្រយុទ្ធ ត្រូវទទួលស្គាល់ជាយោធិនពិការប្រភេទ "ក" វិញ ។

មាត្រា ៦.-

ការវាយតម្លៃប្រភេទថ្នាក់ពិការ ត្រូវធ្វើឡើងដោយក្រុមប្រឹក្សាវាយតម្លៃមួយរបស់ក្រសួងការពារជាតិ ដោយផ្អែកតាមប្រកាសអន្តរក្រសួងរវាងក្រសួងការពារជាតិ ក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

ជំពូកទី ៣

របបឧបត្ថម្ភចំពោះយោធិនពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ

មាត្រា ៧.-

យោធិនពលី ត្រូវបានទទួលរបបឧបត្ថម្ភដូចតទៅ ÷

-ប្រាក់ឧបត្ថម្ភ ស្មើនឹងទឹកប្រាក់ចំនួន ៥ (ប្រាំបួន)ខែ នៃប្រាក់បៀវត្សរ៍សរុបចុងក្រោយរបស់យោធិនពលីជូនដល់គ្រួសារសព ឬកងឯកភាព ដែលទទួលបន្ទុករៀបចំធ្វើបុណ្យបូជា ឬ បញ្ចុះសព

-ប្រាក់ឧបត្ថម្ភមួយលើកដំបូងជូនគ្រួសារសព ស្មើនឹងទឹកប្រាក់ចំនួន ១៥ (ដប់ប្រាំ) ខែ នៃប្រាក់បៀវត្សរ៍សរុប ចុងក្រោយរបស់យោធិនពលី

-ប្រាក់ឧបត្ថម្ភជំនួយគ្រួសារជាប្រចាំខែ ជូនដល់ប្រពន្ធ ឬ ប្តី កូនបង្កើត ឪពុក ម្តាយបង្កើត ឬអ្នកអាណាព្យាបាលរបស់យោធិនពលី តាមប្រកាសអន្តរក្រសួងរវាងក្រសួងការពារជាតិ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយមានការឯកភាពពីរាជរដ្ឋាភិបាល ។

មាត្រា ៨.-

យោធិនមរណៈ ត្រូវបានទទួលរបបឧបត្ថម្ភដូចតទៅ ÷

-ប្រាក់ឧបត្ថម្ភ ស្មើនឹងទឹកប្រាក់ចំនួន ៧ (ប្រាំពីរ) ខែ នៃប្រាក់បៀវត្សរ៍សរុបចុងក្រោយរបស់យោធិនមរណៈ ជូនដល់គ្រួសារសព ឬកងឯកភាព ដែលទទួលបន្ទុករៀបចំធ្វើបុណ្យបូជា ឬ បញ្ចុះសព

-ប្រាក់ឧបត្ថម្ភមួយលើកដំបូងជូនគ្រួសារសពស្មើនឹងទឹកប្រាក់ចំនួន ១២ (ដប់ពីរ) ខែនៃប្រាក់បៀវត្សរ៍សរុបចុងក្រោយរបស់យោធិនមរណៈ

-ប្រាក់ឧបត្ថម្ភជំនួយគ្រួសារប្រចាំខែជូនដល់ប្រពន្ធ ឬប្តី កូនបង្កើត និងឪពុក ម្តាយបង្កើត ឬអ្នកអាណាព្យាបាលរបស់យោធិនមរណៈ តាមប្រកាសអន្តរក្រសួងរវាងក្រសួងការពារជាតិ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយមានការឯកភាពពីរាជរដ្ឋាភិបាល ។

មាត្រា ៩.-

យោធិនបង្កស្លាប់ ត្រូវបានទទួលរបបឧបត្ថម្ភដូចតទៅ ÷

-ប្រាក់ឧបត្ថម្ភស្មើនឹងទឹកប្រាក់ចំនួន ៥ (ប្រាំ)ខែ នៃប្រាក់បៀវត្សរ៍សរុបចុងក្រោយរបស់យោធិនបង្កស្លាប់ ជូនដល់គ្រួសារសព ឬ កងឯកភាព ដែលទទួលបន្ទុករៀបចំធ្វើបុណ្យបូជា ឬ បញ្ចុះសព

-ប្រាក់ឧបត្ថម្ភមួយលើកផ្តាច់ជូនដល់គ្រួសារសពស្មើនឹងទឹកប្រាក់ចំនួន ១២ (ដប់ពីរ)ខែ នៃប្រាក់បៀវត្សរ៍ សរុបចុងក្រោយរបស់យោធិនបង្កស្លាប់ ។

មាត្រា ១០.-

យោធិនបាត់ខ្លួន ត្រូវបានទទួលរបបឧបត្ថម្ភដូចតទៅ ÷

-ប្រាក់ឧបត្ថម្ភជូនគ្រួសារស្មើនឹងទឹកប្រាក់បៀវត្សរ៍សរុបចុងក្រោយ របស់យោធិនបាត់ខ្លួន ដោយគិតទាំងរបបអង្គរប្រចាំខែ ចាប់ពីខែ ឆ្នាំ បាត់ខ្លួនរហូតដល់គម្រប់ ១២ (ដប់ពីរ) ខែ

-ក្រោយ១២(ដប់ពីរ)ខែ គិតពីខែ ឆ្នាំ បាត់ខ្លួនមក គ្រួសារត្រូវបានទទួលប្រាក់ឧបត្ថម្ភដូចជាយោធិនពលី លើកលែងតែប្រាក់ឧបត្ថម្ភសម្រាប់បូជាសព ឬ បញ្ចុះសពចេញ ។

ក្នុងអំឡុងពេលកំពុងទទួលរបបឧបត្ថម្ភណាមួយក្នុងចំណុចទាំងពីរខាងលើ ប្រសិនបើយោធិនបាត់ខ្លួនបានវិលត្រឡប់មកកងឯកភាពដើម ឬ វិលទៅមូលដ្ឋានវិញ ការផ្តល់របបឧបត្ថម្ភត្រូវតែបញ្ឈប់ចាប់ពីខែ ឆ្នាំ ដែលយោធិនបាត់ខ្លួន នោះមានមុខ ។

មាត្រា ១១.-

ជនដែលមានគ្រប់លក្ខណៈសម្បត្តិ ដែលអាចទទួលរបបឧបត្ថម្ភពីយោធិនពលី មរណៈ បង្កស្លាប់ បាត់ខ្លួន មានដូចតទៅ÷

-ឪពុក និងម្តាយបង្កើត ឬអ្នកអាណាព្យាបាលតាំងពីវ័យកុមារ របស់យោធិន បើសិនជាយោធិននោះនៅលីវ

- ប្រពន្ធ ឬ ប្តី របស់យោធិនមានលិខិតអាពាហ៍ពិពាហ៍ ហើយពុំទាន់រៀបអាពាហ៍ពិពាហ៍ជាថ្មីទៀត

- កូនបង្កើត របស់យោធិនមានសំបុត្រកំណើតអាយុ១៨ (ដប់ប្រាំបី) ឆ្នាំចុះ និងមានអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើង ត្រូវមានលិខិតបញ្ជាក់កំពុងបន្តការសិក្សា ហើយពុំទាន់ទទួលនូវអាហារូបករណ៍ ឬ មាន លិខិតបញ្ជាក់ពិការភាព

-ឪពុកម្តាយបង្កើត ឬអ្នកអាណាព្យាបាលដែលមានកូនពលី ឬមរណៈ១(មួយ)នាក់ ឬ ២(ពីរ)នាក់ ឡើងទៅ ត្រូវបានទទួលរបបឧបត្ថម្ភគុណតាមចំនួនកូនដែលបានពលី ឬមរណៈនោះ។

មាត្រា ១២.-

របបឧបត្ថម្ភ ចំពោះយោធិនពិការប្រភេទ " ក " មានដូចតទៅ ÷

១-ក្រោយពេលព្យាបាលជំងឺរបួសជាសះស្បើយ និងមានលំនឹង ត្រូវបានទទួលរបបឧបត្ថម្ភបំប៉នសុខភាពនៅមជ្ឈមណ្ឌលបំប៉នសុខភាព តាមរយៈពេលកំណត់ និងតាមថ្នាក់ពិការគឺ ÷

-ថ្នាក់ទី ១ បានអនុញ្ញាតឱ្យសម្រាកបំប៉នសុខភាពចំនួន ៩០ (កៅសិប)ថ្ងៃ

-ថ្នាក់ទី ២ បានអនុញ្ញាតឱ្យសម្រាកបំប៉នសុខភាពចំនួន ៦០ (ហុកសិប) ថ្ងៃ

-ថ្នាក់ទី ៣ បានអនុញ្ញាតអោយសំរាកបំប៉នសុខភាពចំនួន ៤៥ (សែសិបប្រាំ)ថ្ងៃ

-ថ្នាក់ទី ៤ បានអនុញ្ញាតឱ្យសម្រាកបំប៉នសុខភាពចំនួន ៣០ (សាមសិប) ថ្ងៃ ។

២-ប្រសិនបើយោធិនពិការ នៅបន្តការងារក្នុងកងយោធពលខេមរភូមិន្ទ ត្រូវបានទទួលរបបឧបត្ថម្ភជំនួយមុខរបួសបន្ថែមជាប្រចាំខែ ដោយគិតជាសមាមាត្រភាគរយនៃបៀវត្សរ៍សរុបប្រចាំខែផ្ទាល់ខ្លួន និងតាមកម្រិតថ្នាក់ពិការបន្ថែមលើប្រាក់បៀវត្សរ៍ប្រចាំខែផ្ទាល់ខ្លួន ៖

-ថ្នាក់ទី ១ បានទទួលរបបឧបត្ថម្ភជាទឹកប្រាក់ចំនួនស្មើនឹង៤៥ (សែសិបប្រាំ) ភាគរយនៃប្រាក់បៀវត្សរ៍ផ្ទាល់ខ្លួនចុងក្រោយរបស់យោធិនពិការនោះ

-ថ្នាក់ទី ២ បានទទួលរបបឧបត្ថម្ភជាទឹកប្រាក់ចំនួនស្មើនឹង ៤០ (សែសិប) ភាគរយនៃប្រាក់បៀវត្សរ៍ ផ្ទាល់ខ្លួនចុងក្រោយរបស់យោធិនពិការនោះ

-ថ្នាក់ទី ៣ បានទទួលរបបឧបត្ថម្ភជាទឹកប្រាក់ចំនួនស្មើនឹង ៣៥ (សាមសិបប្រាំ) ភាគរយនៃប្រាក់បៀវត្សរ៍ ផ្ទាល់ខ្លួនចុងក្រោយរបស់យោធិនពិការនោះ

-ថ្នាក់ទី ៤ បានទទួលរបបឧបត្ថម្ភជាទឹកប្រាក់ចំនួនស្មើនឹង ៣០ (សាមសិប) ភាគរយនៃប្រាក់បៀវត្សរ៍ ផ្ទាល់ខ្លួនចុងក្រោយ របស់យោធិនពិការនោះ ។

៣-យោធិនពិការ ដែលក្រសួងការពារជាតិសម្រេចអោយចេញពីជួរកងយោធពលខេមរភូមិន្ទ ត្រូវបាន ទទួលរបបឧបត្ថម្ភប្រាក់អតីតភាពបម្រើការងារមិនលើសពី ២៤ (ម្ភៃបួន) ខែ ដោយគិតរយៈពេលបម្រើកងយោធពលខេមរភូមិន្ទក្នុង១ (មួយ) ឆ្នាំ ត្រូវបានទទួលប្រាក់ឧបត្ថម្ភអតីតភាពចំនួន ២ (ពីរ) ខែ។ ចំពោះយោធិនពិការដែលបម្រើកងទ័ពមិនទាន់គ្រប់រយៈពេល ១ (មួយ) ឆ្នាំ ហើយត្រូវពិការ ក៏ត្រូវបានទទួលប្រាក់អតីតភាពចំនួន ២ (ពីរ) ខែ ដែរ ។

៤-យោធិនពិការ ត្រូវបានទទួលរបបឧបត្ថម្ភមួយលើកដំបូងស្មើនឹងទឹកប្រាក់ចំនួន ៖

-ថ្នាក់ទី ១ ទទួលទឹកប្រាក់សរុបចំនួន ១២ (ដប់ពីរ) ខែ នៃប្រាក់បៀវត្សរ៍សរុប ចុងក្រោយរបស់យោធិន ពិការនោះ

-ថ្នាក់ទី ២ ទទួលទឹកប្រាក់សរុបចំនួន ១០ (ដប់) ខែ នៃប្រាក់បៀវត្សរ៍សរុបចុងក្រោយរបស់យោធិន ពិការនោះ

-ថ្នាក់ទី ៣ ទទួលទឹកប្រាក់សរុបចំនួន ៨ (ប្រាំបី) ខែ នៃប្រាក់បៀវត្សរ៍សរុបចុងក្រោយរបស់យោធិន ពិការនោះ

-ថ្នាក់ទី ៤ ទទួលទឹកប្រាក់សរុបចំនួន ៦ (ប្រាំមួយ) ខែ នៃប្រាក់បៀវត្សរ៍សរុបចុងក្រោយរបស់យោធិន ពិការនោះ ។

៥-បានបន្តទទួលបើកប្រាក់បៀវត្សរ៍សរុបប្រចាំខែ ហើយបៀវត្សរ៍សរុបនោះ ត្រូវគិតតាមឋានន្តរសក្តិចុងក្រោយមុនពេលសម្រេចឱ្យចេញពីជួរកងយោធពលខេមរភូមិន្ទ - និងចំនួនកូននៅក្នុងបន្ទុក

ជាក់ស្តែង របស់យោធិនពិការ ។

៦-យោធិនពិការ ដែលរស់នៅក្នុងមណ្ឌល យោធិនដែលចេញពីជួរកងយោធពលខេមរភូមិន្ទ ត្រូវបាន ទទួលបន្ថែមនូវប្រាក់ឧបត្ថម្ភជំនួយមុខរបួសជារៀងរាល់ខែ ដោយគិតជាសមាមាត្រលើប្រាក់បៀវត្សរ៍សរុប ប្រចាំខែ ដូចខាងក្រោម ÷

-ថ្នាក់ទី ១ ទទួលបានប្រាក់ឧបត្ថម្ភមុខរបួសស្មើនឹង ១០០ (មួយរយ) ភាគរយ

-ថ្នាក់ទី ២ ទទួលបានប្រាក់ឧបត្ថម្ភមុខរបួសស្មើនឹង ៨០ (ប៉ែតសិប) ភាគរយ

-ថ្នាក់ទី ៣ ទទួលបានប្រាក់ឧបត្ថម្ភមុខរបួសស្មើនឹង ៦០ (ហុកសិប) ភាគរយ

-ថ្នាក់ទី ៤ ទទួលបានប្រាក់ឧបត្ថម្ភមុខរបួសស្មើនឹង ៤០ (សែសិប) ភាគរយ ។

៧-យោធិនពិការកម្រិតថ្នាក់១ បានទទួលរបបឧបត្ថម្ភអ្នកបំរើផ្ទាល់ខ្លួនមួយនាក់ ហើយអ្នកបម្រើនោះ ត្រូវបានទទួលជាប្រចាំខែ រហូតដល់យោធិននោះស្លាប់ ស្មើនឹងបៀវត្សរ៍អប្បបរមាផ្ទាល់ខ្លួនរបស់យោធិនមាន ឋានន្តរសក្តិ ជាពលទោ ។

មាត្រា ១៣.-

របបឧបត្ថម្ភ ចំពោះយោធិនពិការប្រភេទ " ខ " មានដូចតទៅ ÷

១-យោធិនពិការដែលក្រសួងការពារជាតិសម្រេចឱ្យចេញពីជួរកងយោធពលខេមរភូមិន្ទ នឹងបាន ទទួលប្រាក់ឧបត្ថម្ភអតីតភាពបម្រើការងារមិនលើសពី ៨(ប្រាំបី)ខែ ដោយគិតរយៈពេលបម្រើកងយោធពល-ខេមរភូមិន្ទ ក្នុង ១(មួយ)ឆ្នាំ ត្រូវបានទទួលប្រាក់ឧបត្ថម្ភអតីតភាពចំនួន ២(ពីរ)ខែ ។ ចំពោះយោធិនពិការ ដែលបម្រើកងទ័ពមិនទាន់គ្រប់រយៈពេល ១(មួយ)ឆ្នាំ ហើយត្រូវពិការក៏ត្រូវបានទទួលប្រាក់អតីតភាពចំនួន២ (ពីរ)ខែ ដែរ ។

២-យោធិនពិការ ត្រូវបានទទួលរបបឧបត្ថម្ភជាប្រចាំតាមថ្នាក់ពិការ តាមសមាមាត្រភាគរយនៃ ប្រាក់បៀវត្សរ៍ផ្ទាល់ខ្លួនចុងក្រោយរបស់យោធិនពិការ ÷

-ថ្នាក់ទី ១ បានទទួលទឹកប្រាក់សរុបស្មើនឹង ៩០ (កៅសិប) ភាគរយនៃបៀវត្សរ៍ផ្ទាល់ ខ្លួនចុងក្រោយរបស់យោធិនពិការនោះ

-ថ្នាក់ទី ២ បានទទួលទឹកប្រាក់សរុបស្មើនឹង ៨០ (ប៉ែតសិប) ភាគរយនៃបៀវត្សរ៍ផ្ទាល់ ខ្លួនចុងក្រោយរបស់យោធិនពិការនោះ

-ថ្នាក់ទី ៣ បានទទួលទឹកប្រាក់សរុបស្មើនឹង ៧០ (ចិតសិប) ភាគរយនៃបៀវត្សរ៍ផ្ទាល់ ខ្លួនចុងក្រោយរបស់យោធិនពិការនោះ

-ត្រូវបានទទួលឧបត្ថម្ភចិញ្ចឹមប្រពន្ធ ឬប្តី កូន ដូចយោធិនពិការប្រភេទ " ក " ។

មាត្រា ១៤.-

យោធិនពិការទាំង ២ ប្រភេទ គ្រប់ថ្នាក់ ត្រូវបានទទួលរបបឧបត្ថម្ភបន្ថែមដូចតទៅ ÷

១-រាល់ថ្ងៃបុណ្យចូលឆ្នាំខ្មែរ បុណ្យភ្ជុំបិណ្ឌ និងថ្ងៃបុណ្យខួបរំលឹកគុណយោធិនពលី ពិការ (កំណត់ថ្ងៃបុណ្យភ្ជុំបិណ្ឌ) ត្រូវបានទទួលរបបឧបត្ថម្ភស្មើនឹងទឹកប្រាក់ឧបត្ថម្ភថ្ងៃបុណ្យរបស់មន្ត្រីរាជការកំពុងធ្វើការងារ ។

២-ពេលមានជំងឺ របួស ឬ ពេលរបួសសើរើ ត្រូវបានទទួលសង្គ្រោះព្យាបាលលុះជាសះស្បើយ នៅតាមមន្ទីរពេទ្យរដ្ឋ ដោយឥតគិតថ្លៃ ។

៣-យោធិនពិការទាំងពីរភេទ ត្រូវបានរដ្ឋជួយស្តារលទ្ធភាពពលកម្ម កាយសម្បទា និងផ្តល់ឧបករណ៍ទ្រទ្រង់រាងកាយ ដោយឥតបង់ប្រាក់ ជួយបណ្តុះបណ្តាលវិជ្ជាជីវៈ និងបង្កឱ្យមានមុខរបរសមស្របតាមសមត្ថភាព និងលទ្ធភាពជាក់ស្តែង ។

៤-យោធិននារីពិការ ត្រូវបានទទួលឧបត្ថម្ភបន្ថែមនូវការធានារ៉ាប់រងសង្គមដូចស្ត្រីដែលកំពុងបម្រើការងាររាជការដែរ ។

៥-យោធិនពិការ ដែលបម្រើការងារនៅពេលគ្រប់លក្ខណៈសម្បត្តិចូលនិវត្តន៍ ត្រូវផ្ទេរទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីដោះស្រាយប្រាក់ឧបត្ថម្ភជំនួយមុខរបួស និងប្រាក់សោធននិវត្តន៍វិញ ។

ជំពូកទី ៤

ការទទួលខុសត្រូវលើរបបឧបត្ថម្ភចំពោះយោធិនពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ

មាត្រា ១៥.-

ក្រសួងការពារជាតិ ជាអ្នកទទួលបន្ទុកដោះស្រាយនូវរាល់ការចំណាយដូចខាងក្រោម ÷

- សម្រាប់ការបូជា ឬបញ្ចុះសព
- សម្រាប់ឧបត្ថម្ភជូនគ្រួសារយោធិនពលី មរណៈ បង្កស្លាប់ មួយលើកដំបូង
- សម្រាប់ឧបត្ថម្ភបំប៉នសុខភាពយោធិនពិការ
- សម្រាប់ឧបត្ថម្ភប្រាក់អតីតភាពការងាររបស់យោធិនពិការ មុនពេលសម្រេចឱ្យចេញពីជួរកងយោធពលខេមរភូមិន្ទ
- សម្រាប់ឧបត្ថម្ភជំនួយមុខរបួសរបស់យោធិនពិការ នៅបន្តការងារក្នុងកងយោធពល-ខេមរភូមិន្ទ

- ដោះស្រាយប្រាក់បៀវត្សរ៍សរុប ៣ (បី) ខែ មុនពេលផ្ទេរយោធិនពិការទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងរយៈពេលរង់ចាំ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បំពេញសំណុំលិខិតដោះស្រាយប្រាក់ឧបត្ថម្ភបន្ត ។

មាត្រា ១៦.-

ក្រៅពីរបបឧបត្ថម្ភ ដែលក្រសួងការពារជាតិទទួលបន្ទុកដោះស្រាយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាអ្នកទទួលបន្ទុកដោះស្រាយបន្ត ។

ជំពូកទី ៥

អវសានប្បញ្ញត្តិ

មាត្រា ១៧.-

អនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ និងអនុក្រឹត្យលេខ ០២ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៥ ស្តីពីរបបឧបត្ថម្ភចំពោះយោធិនពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៨.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយក រដ្ឋមន្ត្រី
- ដូចមាត្រា ១៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការនៅខេត្តកំពង់ឆ្នាំង ចំនួន ៣៨ នាក់ ដែលមានស្នាដៃឆ្នើម ក្នុងការបំពេញភារកិច្ចក្នុងឆ្នាំ ២០០៦ ដូចមានរាយនាមខាងក្រោមនេះ :

ក-មេដាយមាសការងារ

១-លោក	**អ៊ុក ឌីម**	អគ្គលេខាធិការសាលាខេត្តកំពង់ឆ្នាំង
២-លោក	**អ៊ុក ភីឡា**	ប្រធានអង្គភាពរដ្ឋបាលមូលដ្ឋានសាលាខេត្តកំពង់ឆ្នាំង
៣-លោក	**សុ សារ៉េត**	អភិបាលរងស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង
៤-លោក	**នូ ណារ៉ុង**	ប្រធានក្រុមហិរញ្ញវត្ថុសាលាខេត្តកំពង់ឆ្នាំង

ខ-មេដាយប្រាក់ការងារ

១-លោក	**យិន សាវ៉េន**	អភិបាលរងស្រុកជលគីរី ខេត្តកំពង់ឆ្នាំង

២-លោក	ស៊ឹម សារ៉េន	អភិបាលរងស្រុកជលគីរី ខេត្តកំពង់ឆ្នាំង
៣-លោក	អោម សំអឿន	អភិបាលរងស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង
៤-លោក	កៅ ហុន	អភិបាលរងស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង
៥-លោក	ម៉ែន ផល្លា	អភិបាលរងស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង
៦-លោក	សូ ធារិន	អភិបាលរងស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង
៧-លោក	គីម វ៉ាន់នី	អភិបាលរងស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង
៨-លោក	ឃួន ស៊ីណន	អនុប្រធានទី ១ ក្រុមហិរញ្ញវត្ថុសាលាខេត្តកំពង់ឆ្នាំង
៩-លោក	សុខ យ៉ាង	ប្រធានការិយាល័យកិច្ចការសង្គមកិច្ចសាលាខេត្តកំពង់ឆ្នាំង
១០-លោក	ឃួន សៅរី	អភិបាលរងស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង
១១-លោក	ជា ស៊ុនហៀង	ប្រធានការិយាល័យសាលាស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង
១២-លោក	ខាង ស៊ីខេម	អភិបាលរងស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង
១៣-លោក	ស៊ឹម សោភ័ណ	អភិបាលរងស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង

គ. មេដាយសេរីវឌ្ឍនភាពមាស

១-លោក	ម៉ែន ស៊ីយ៉ាន	អនុប្រធានទី១ការិយាល័យពត៌មានសាលាខេត្តកំពង់ឆ្នាំង
២-លោក	លឿង សុភាព	អនុប្រធានការិយាល័យរបៀប-ឯកសារសាលាខេត្តកំពង់ឆ្នាំង
៣-លោក	វ៉ាន់ សារឿន	អនុប្រធានការិយាល័យសាលាខេត្តកំពង់ឆ្នាំង
៤-លោក	សៅ កៅ	អនុប្រធានទី១ការិយាល័យកិច្ចការទូទៅ សាលាខេត្តកំពង់ឆ្នាំង
៥-លោក	ហាឡូ ពិសី	អនុប្រធានការិយាល័យកិច្ចការសេដ្ឋកិច្ចសាលាខេត្តកំពង់ឆ្នាំង
៦-លោក	មិច ឆុន	អនុប្រធានការិយាល័យកិច្ចការសេដ្ឋកិច្ចសាលាខេត្តកំពង់ឆ្នាំង
៧-លោក	ពេញ ស៊ីយ៉ាន	អនុប្រធានទី១ការិ/កិច្ចការតុលាការ សាលាខេត្តកំពង់ឆ្នាំង
៨-លោក	ឈីន ស្រួច	អនុប្រធានទី១ការិយាល័យចំណាយ សាលាខេត្តកំពង់ឆ្នាំង
៩-លោក	នៅ រដ្ឋា	អនុប្រធានការិយាល័យគណនេយ្យ សាលាខេត្តកំពង់ឆ្នាំង
១០-លោក	អ៊ី ចេង	មន្ត្រីពន្ធនាគារខេត្តកំពង់ឆ្នាំង
១១-លោក	អោក សុភារី	ប្រធានការិយាល័យសាលាស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង
១២-លោក	ទង សានស៊ុនលី	ប្រធានការិយាល័យសាលាស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង
១៣-លោក	អ៊ុន គីមសាន្ត	ប្រធានការិយាល័យសាលាស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង
១៤-លោក	ជួប វិចិត្រ	អនុប្រធានមន្ទីរស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង
១៥-លោក	ជា ម៉េង	ប្រធានការិយាល័យសាលាស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង
១៦-លោក	ណែម នាង	អនុប្រធានមន្ទីរស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង
១៧-លោក	សុខ វិចិត្រ	ប្រធានការិយាល័យសាលាស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង
១៨-លោក	សោម ម៉េង	ប្រធានការិយាល័យសាលាស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង
១៩-លោក	តូច ហេង	អនុប្រធានមន្ទីរស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង

២០-លោក **ម៉ែន សិរី** ប្រធានការិយាល័យសាលាស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង

២១-លោក **ឡុច ស៊ិន** ប្រធានការិយាល័យសាលាស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង

មាត្រា ២ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១ និងមាត្រា ២*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៦៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការនៅខេត្តពោធិ៍សាត់ចំនួន ៣០ នាក់ ដែលមានស្នាដៃឆ្នើមក្នុងការបំពេញភារកិច្ចក្នុងឆ្នាំ ២០០៦ ដូចមានរាយនាមខាងក្រោមនេះ :

ក.មេដាយមាសការងារ

១-លោក	**ស៊ឹម សុវណ្ណ**	អធិការរងទី ១ នៃក្រុមអធិការកិច្ចសាលាខេត្តពោធិ៍សាត់
២-លោក	**ជា ប៊ុនឈន**	អភិបាលរងស្រុកសំពៅមាស ខេត្តពោធិ៍សាត់
៣-លោក	**សោម ទិសាល**	អភិបាលរងស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់
៤-លោក	**ខឹម ឆួក**	អភិបាលរងស្រុកវាលវែង ខេត្តពោធិ៍សាត់
៥-លោក	**សោម សៃ**	ប្រធានការិយាល័យសរុប សាលាខេត្តពោធិ៍សាត់
៦-លោក	**សាន សុផល**	អនុប្រធានទី ១ ក្រុមហិរញ្ញវត្ថុសាលាខេត្តពោធិ៍សាត់

ខ.មេដាយប្រាក់ការងារ

១-លោក	**យៀប ឡាច**	ប្រធានការិយាល័យចំណូល សាលាខេត្តពោធិ៍សាត់
២-លោក	**ង៉ែត សីលា**	ប្រធានការិយាល័យស្ថិតិអត្រានុកូលដ្ឋាន សាលាខេត្តពោធិ៍សាត់

៤-លោក	ជា ចំរើន	អនុប្រធានការិយាល័យចំណាយ សាលាខេត្តពោធិ៍សាត់
៥-លោក	ពេជ្រ ចិន្តា	អនុប្រធានការិយាល័យពតិមាន សាលាខេត្តពោធិ៍សាត់
៦-លោក	ជា ស៊ីផាន់ណារ៉ា	អភិបាលរងស្រុកកណ្តៀង ខេត្តពោធិ៍សាត់
៧-លោក	ម៉ម សារ៉ិត	អភិបាលរងស្រុកភ្នំក្រវ៉ាញ ខេត្តពោធិ៍សាត់
៨-លោក	ហ៊ីង ខ៉ាយ	អភិបាលរងស្រុកវាលវែង ខេត្តពោធិ៍សាត់
៩-លោក	ចិន មាន	ប្រធានមន្ទីរស្រុកសំពៅមាស ខេត្តពោធិ៍សាត់
១០-លោក	ពិន មួន	ប្រធានមន្ទីរស្រុកក្រគរ ខេត្តពោធិ៍សាត់
១១-លោក	ហៃ ស៊ីម៉េង	អនុប្រធានការិយាល័យសាលាស្រុកបាកាន ខេត្តពោធិ៍សាត់

គ-<u>មេដាយសិរីវឌ្ឍិការងារ</u>

១-លោក	ម៉ុង សេង	មន្ត្រីអគ្គលេខាធិការដ្ឋានសាលាខេត្តពោធិ៍សាត់
២-លោក	សែត ហៀប	អនុប្រធានអង្គភាពរដ្ឋបាលមូលដ្ឋានសាលាខេត្តពោធិ៍សាត់
៣-លោកស្រី	ខៀវ សោភ័ណ	មន្ត្រីសាលាខេត្តពោធិ៍សាត់
៤-លោក	ម៉ម ផាន់ណា	មន្ត្រីសាលាខេត្តពោធិ៍សាត់
៥-លោក	សរ ប្លែក	ប្រធានការិយាល័យសាលាស្រុកក្រគរ ខេត្តពោធិ៍សាត់
៦-លោក	សុខ ឃន	អនុប្រធានការិយាល័យសាលាស្រុកក្រគរ ខេត្តពោធិ៍សាត់
៧-លោក	សយ លាភ	ស្មៀនឃុំបឹងខ្នារ ស្រុកបាកាន ខេត្តពោធិ៍សាត់
៨-លោក	អែម យ៉ុន	អនុប្រធានការិយាល័យសាលាស្រុកបាកាន ខេត្តពោធិ៍សាត់
៩-លោក	ម៉េង រិទ្ធី	មន្ត្រីសាលាស្រុកបាកាន ខេត្តពោធិ៍សាត់
១០- កញ្ញា	សោម សុន្ទរតនា	អនុប្រធានការិយាល័យសាលាស្រុកសំពៅមាស ខេត្តពោធិ៍សាត់
១១-លោក	ជួន គឿន	ប្រធានការិយាល័យសាលាស្រុកវាលវែង ខេត្តពោធិ៍សាត់
១២-លោក	ឡាំ សុផល	អនុប្រធានការិយាល័យសាលាស្រុកភ្នំក្រវ៉ាញ ខេត្តពោធិ៍សាត់
១៣-កញ្ញា	ចែត ថានី	ស្មៀនឃុំស្យា ស្រុកកណ្តៀង ខេត្តពោធិ៍សាត់

មាត្រា ២ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៧

ហ៊ុន សែន

<u>**កន្លែងទទួល :**</u>

ក្រសួងព្រះបរមរាជវាំង
គ្គលេខាធិការដ្ឋានព្រឹទ្ធសភា
គ្គលេខាធិការដ្ឋានរដ្ឋសភា
អគ្គលេខាធិការរាជរដ្ឋាភិបាល
ទ្ធកាល័យសម្តេចនាយករដ្ឋមន្ត្រី
ចមាត្រា ១ និងមាត្រា ២
កសារ កាលប្បវត្តិ √

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៦៥. អនក្រ. បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ
១ ០៣
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនមន្ត្រី បុគ្គលិក សមាជិក សមាជិកា និងសប្បុរសជន សាខាកាកបាទក្រហមកម្ពុជា ខេត្តក្រចេះ ខេត្តមណ្ឌលគិរី ខេត្តឧត្តរមានជ័យ ខេត្តព្រះវិហារខេត្តស្ទឹងត្រែង ខេត្តរតនៈគិរី ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ចាម ខេត្តស្វាយរៀង ក្រុងកែប ខេត្តពោធិសាត់ ខេត្តកំពង់ធំ ខេត្តព្រៃវែង ក្រុងប៉ៃលិន និងខេត្តសៀមរាប ចំនួន៤៥៥រូប ដែលមានស្នាដៃល្អក្នុងការបំរើការងារមនុស្សធម៌ ជូនកាកបាទក្រហមកម្ពុជាកន្លងមក ដូចមានរាយនាមខាងក្រោម :-

១-លោក	ឃុន គ្រី	ប្រធានគណៈកម្មាធិការ សាខាកក្រ.ក ខេត្តក្រចេះ
២-លោកជំទាវ	ត្រឹង ចារី	អនុប្រធានគណៈកម្មាធិការ សាខាកក្រ.ក ខេត្តក្រចេះ
៣-លោក	នួច ហៀន	ហេរញ្ញិកគណៈកម្មាធិការ សាខាកក្រ.ក ខេត្តក្រចេះ
៤-លោកជំទាវ	ចាន់ លី	សមាជិកាគណៈកម្មាធិការ សាខាកក្រ.ក ខេត្តក្រចេះ (ភរិយា ឯកឧត្តម ខាំ ភឿន អភិបាលខេត្តក្រចេះ)
៥-លោកស្រី	ហោ គីមខេន	សមាជិកាគណៈកម្មាធិការ សាខាកក្រ.ក ខេត្តក្រចេះ
៦-លោកស្រី	ស៊ុន គីមញាណ	សមាជិកាគណៈកម្មាធិការ សាខាកក្រ.ក ខេត្តក្រចេះ
៧-លោក	រឹម យ៉ាន	សមាជិកគណៈកម្មាធិការ សាខាកក្រ.ក ខេត្តក្រចេះ
៨-លោក	គាច ម៉ាច	សមាជិកគណៈកម្មាធិការ សាខាកក្រ.ក ខេត្តក្រចេះ
៩-លោកវេជ្ជ.	ចាន់ សារ៉ម	សមាជិកគណៈកម្មាធិការ សាខាកក្រ.ក ខេត្តក្រចេះ

១០-លោក	ទេវង ធីរ៉ាដា	នាយក សាខាកក្រ.ក ខេត្តក្រចេះ
១១-លោក	ម៉ូ សេងឡុង	បុគ្គលិកអភិវឌ្ឍន៍ សាខាកក្រ.ក ខេត្តក្រចេះ
១២-លោកស្រី	ទ្រាក់ សុគន្ធា	បុគ្គលិកអភិវឌ្ឍន៍ សាខាកក្រ.ក ខេត្តក្រចេះ
១៣-លោក	ម៉ិច ផាន	បុគ្គលិកស្រាវជ្រាវរកគ្រួសារ និង គ្រាប់មិនទាន់ផ្ទុះ សាខាកក្រ.ក ខេត្តក្រចេះ
១៤-លោក	ទិល សារុំ	ឆ្មាំឃ្លាំង សាខាកក្រ.ក ខេត្តក្រចេះ
១៥-លោក	ម៉ី ឆន	សមាជិកប្រចាំការ អនុសាខាកក្រ.ក ស្រុកស្នួល ខេត្តក្រចេះ
១៦-លោក	ឡុង មេង ឃួន	សមាជិកប្រចាំការ អនុសាខាកក្រ.ក ស្រុកក្រចេះ ខេត្តក្រចេះ
១៧-លោក	ជូ ហ៊ឹន	សមាជិកប្រចាំការ អនុសាខាកក្រ.ក ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ
១៨-លោកស្រី	ឆាយ ស្រ៊ុន	សមាជិកាប្រចាំការ អនុសាខាកក្រ.ក ស្រុកសំបូរ ខេត្តក្រចេះ
១៩-លោកវរ.ឯក	យឹម យ៉ាន	សប្បុរសជន (មេបញ្ជាការតំបន់ប្រតិបត្តិការសឹក ខេត្តក្រចេះ)
២០-ឯកឧត្តម	ម៉ិច សុខណ្ណ	សប្បុរសជន (ប្រធានអគ្គនាយកចំការកៅស៊ូ ស្នួល)
២១-លោកស្រី	ស៊ុន សក្ខិណា	ទីប្រឹក្សាយុវជន វិ.ព្រះមហាក្សត្រីយានីកុសុមៈ ក្រចេះក្រុង ខេត្តក្រចេះ
២២-លោក	នូ ដង្កូន	ទីប្រឹក្សាយុវជន អនុវិទ្យាល័យក្រចេះក្រុង ខេត្តក្រចេះ
២៣-លោក	នន សារ៉ាន	ទីប្រឹក្សាយុវជន អនុវិ.ព្រះអង្គម្ចាស់ក្សត្រីមុនីកេសរ ឆ្លូង ខេត្តក្រចេះ
២៤-លោកស្រី	អោះ ប៊ុនស៊ាន	ទីប្រឹក្សាយុវជន អនុវិ.ព្រះអង្គម្ចាស់ក្សត្រីមុនីកេសរ ឆ្លូង ខេត្តក្រចេះ
២៥-លោក	អ៊ិន រ៉ូម៉ិន	ទីប្រឹក្សាយុវជន អនុវិទ្យាល័យ ហ៊ុន សែនសម្បុកៈសំបូរ ខេត្តក្រចេះ
២៦-លោកស្រី	ម៉ិច ស៊ីមចាង	ទីប្រឹក្សាយុវជន សាលាបឋមសិក្សាគារកណ្តាល ខេត្តក្រចេះ
២៧-លោក	ជុន ម៉េង	ទីប្រឹក្សាយុវជន សាលាបឋម ២៤ កញ្ញា អូរឬស្សី ខេត្តក្រចេះ
២៨-លោក	ស៊ិន សុផាន់ណា	បុគ្គលិកទំនាក់ទំនង មន្ទីរអប់រំយុវជននិងកីឡា ខេត្តក្រចេះ
២៩-លោកស្រី	អ៊ុក ម៉ិណ្ណារី	អ្នកស្ម័គ្រចិត្ត សាខាកក្រ.ក ឃុំឆ្លូង ខេត្តក្រចេះ
៣០-លោក	ម៉ី ណារី	អ្នកស្ម័គ្រចិត្ត សាខាកក្រ.ក ឃុំអូរឬស្សី ខេត្តក្រចេះ
		6261	សោហ៊ុយប្រៃសណីយ៍
		6262	សោហ៊ុយទូរគមនាគមន៍
	627		សោហ៊ុយធនាគារ
	628		សោហ៊ុយផ្សេងៗ
64			**បន្ទុកបុគ្គលិក**
	641		លាភការ និង ប្រាក់បំណាច់ នៃអំណាចសាធារណៈ
		6411	ប្រាក់បំណាច់អភិបាលខេត្ត-ក្រុង
		6412	ប្រាក់បំណាច់អភិបាលរងខេត្ត-ក្រុង
		6413	លាភការទីប្រឹក្សា
		6414	លាភការបេសកជន
		6419	ការសង និងការបង្វិលវិញ
	642		លាភការនិងប្រាក់បំណាច់បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ
		6421	បៀវត្សមូលដ្ឋាន
			. ចំនួន
			. ប្រភេទ
			. ខុទ្ទកាល័យ
		6422	ប្រាក់បំណាច់មុខងារ
		6423	ប្រាក់បំណាច់ម៉ោងបន្ថែម
		6424	ប្រាក់បំណាច់តំបន់
		6425	ប្រាក់បំណាច់ទទួលខុសត្រូវ
		6426	ប្រាក់បំណាច់ការងារធ្ងន់ និងប៉ះពាល់សុខភាព
		6429	ការសង និងការបង្វិលវិញ
	643		រង្វាន់ និងប្រាក់បំណាច់ផ្សេងៗទៀត
		6431	កន្សោមអធិភាព
		6432	ប្រាក់បំណាច់សំរាប់ប្រឡង-ប្រឡងប្រជែង
		6433	រង្វាន់
		6434	ប្រាក់បំណាច់បុគ្គលិកក្រសួងផ្សេងៗ
		6438	ផ្សេងៗ
		6439	ការសង និងការបង្វិលវិញ
	644		លាភការ និងប្រាក់បំណាច់បុគ្គលិកមិនមែនក្របខ័ណ្ឌ និងបុគ្គលិកអណ្តែត
		6441	បៀវត្សមូលដ្ឋានបុគ្គលិកមិនមែនក្របខ័ណ្ឌ
		6442	លាភការផ្សេងៗទៀតបុគ្គលិកមិនមែនក្របខ័ណ្ឌ
		6443	បៀវត្សមូលដ្ឋានបុគ្គលិកអណ្តែត
		6444	លាភការផ្សេងៗទៀតបុគ្គលិកអណ្តែត
		6449	ការសង និងការបង្វិលវិញ
	645		ប្រាក់វិភាជន៍សង្គម
		6451	ប្រាក់បំណាច់ជាលក្ខណៈគ្រួសារ
			. កូនមានអាយុតិចជាង១៥ ឆ្នាំ
			. កូនរៀនវិទ្យាល័យ អនុវិទ្យាល័យ
			. ប្រាក់បំណាច់អ្នកក្នុងបន្ទុក
		6452	មន្ត្រីមានជំងឺ និងឧបត្ថម្ភអ្នកសំរាលកូន
		6453	មរណៈភាព
		6454	ឧបត្ថម្ភនិវត្តជន
		6455	ឧបត្ថម្ភដល់អ្នកសុំឈប់ពីការងារ

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ
		6456	គ្រោះថ្នាក់ការងារ និងទុព្វលភាព
		6457	ឧបត្ថម្ភដល់កូនកំព្រារបស់មន្ត្រីរាជការ
		6458	ផ្សេងៗ
		6459	ការសង និងការបង្វិលវិញ
			ប្រភេទទី ២ : បន្ទុកហិរញ្ញវត្ថុ
66			**បន្ទុកហិរញ្ញវត្ថុ**
			ប្រភេទទី ៣ : អន្តរាគមន៍សាធារណៈ
65			**ឧបត្ថម្ភកធន និងជំនួយសង្គម**
	651		ឧបត្ថម្ភកធនដល់រដ្ឋបាលដែនដី
		6511	ឧបត្ថម្ភកធនស្រុក ខណ្ឌ
		6512	ឧបត្ថម្ភកធនដល់ឃុំ សង្កាត់
		6513	ឧបត្ថម្ភគ្រឹះស្ថានសាធារណៈរដ្ឋបាល
	652		ជំនួយសង្គមនិងប្រាក់វិភាជន៍
		6521	ជំនួយដល់ប្រជាជនក្រីក្រសំរាកពេទ្យ
		6522	ជួយជនរងគ្រោះដោយធម្មជាតិ
		6528	ចំណាយសង្គមផ្សេងៗទៀត
	653		ឧបត្ថម្ភកធនដល់អង្គភាពមានលក្ខណៈសង្គមនិងវប្បធម៌
		6531	ឧបត្ថម្ភមណ្ឌលកុមារកំព្រា
		6532	ឧបត្ថម្ភសហគមន៍ កីឡា និងវប្បធម៌
		6533	ឧបត្ថមកាកបាទក្រហម
			ប្រភេទទី ៤ : ចំណាយផ្សេងៗ
63			**ពន្ធ និង អាករ**
	631		លតាប័ត្រ
			ខ.ក្រុមទី ២ : ចំណាយតាមដីកា និងចំណាយមិនបានគ្រោងទុក (ប្រភេទទី៥ + ប្រភេទទី៦)
			ប្រភេទទី ៥ : ចំណាយតាមដីកា (មិនឆ្លងសាច់ប្រាក់)
67			**បន្ទុកពិសេស**
	671		ឥណទេយ្យដែលទទួលស្គាល់តែទារមិនបាន
	675		តំលៃគណនេយ្យនៃចំណែកសកម្មបានលក់ (តំលៃនៅសល់)
68			**ទាយជ្ជទានអោយដល់រំលស់អចលកម្ម**
	681		ទាយជ្ជទានអោយដល់រំលស់អចលកម្មអរូបី
	682		ទាយជ្ជទានអោយដល់រំលស់អចលកម្មរូបី
			ប្រភេទទី ៦ : ចំណាយមិនបានគ្រោងទុក

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ
09			**ចំណាយមិនបានគ្រោងទុក**
			II - សរុបចំណាយជាមូលធន
			ក. ក្រុមទី ១ : ចំណាយពិត (ប្រភេទទី១ + ប្រភេទទី២)
			ប្រភេទទី ១ : អចលកម្ម
20			**អចលកម្មអរូបី**
	203		សោហ៊ុយសិក្សា ស្រាវជ្រាវ និង អភិវឌ្ឍន៍
	205		ប្រកាសនីយប័ត្រ.អាជ្ញាប័ណ្ណនិងសិទ្ធិប្រហាក់ប្រហែល
21			**អចលកម្មរូបី**
	211		ដីធ្លី និងធនធានធម្មជាតិ
	212		ការរៀបចំកែលំអរដីធ្លី
	213		សំណង់
		2131	អាគារ
		2132	ការរៀបចំកែលំអរអាគារ
		2138	សំណង់ផ្សេងៗទៀត
	214		ហេដ្ឋារចនាសម្ព័ន្ធ
		2141	បណ្តាញបង្ហូរទឹក និងអនាម័យ
		2142	បណ្តាញអគ្គិសនី
		2143	បណ្តាញធារាសាស្ត្រ
		2144	បណ្តាញផ្លូវថ្នល់
	215		ឋបនកម្មបច្ចេកទេស សំភារៈ និងឧបករណ៍
		2151	ឋបនកម្មបច្ចេកទេស
		2152	សំភារៈ
		2153	គ្រឿងឧបករណ៍ (ហត្ថឧបករណ៍)
	218		អចលកម្មរូបីផ្សេងទៀត
		2181	សំភារៈឧបករណ៍ដឹកជញ្ជូន
		2182	សំភារៈឧបករណ៍ការិយាល័យ
		2183	សំភារៈពត៌មានវិទ្យា និងទូរគមនាគមន៍
		2184	សត្វពាហនៈ
		2188	ផ្សេងៗ
			ខ. ក្រុមទី ២ : ចំណាយតាមដីកា
			ប្រភេទទី ២ : ចំណាយតាមដីកា

ឧបសម្ព័ន្ធ១

មាតិកាចំណូលថវិកាស្រុក_ខណ្ឌ

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណូល
			សរុបរួមចំណូលថវិកាស្រុក_ខណ្ឌ
			I - សរុបចំណូលចរន្ត
			ក. ក្រុមទី១ : ចំណូលពិត (ប្រភេទទី១ + ប្រភេទទី២)
			ប្រភេទទី ១: ចំណូលសារពើពន្ធ
70			**ចំណូលសារពើពន្ធ**
			ប្រភេទទី ២: ចំណូលមិនមែនសារពើពន្ធ
72			**ផលទុននៃទ្រព្យសម្បត្តិរដ្ឋ**
73			**ផលទុនលើការលក់-ជួលទ្រព្យសម្បត្តិនិងសេវា**
	732		ផលពីការគ្រប់គ្រងរដ្ឋបាល
		7321	សេវាសុរិយោដី
		7322	សេវាសំណង់
		7323	ចំណូលសំរាប់ទំរង់ការរដ្ឋបាល
		7324	ចំណូលពីការអនុញ្ញាតរដ្ឋបាល
		7328	ចំណូលរដ្ឋបាលផ្សេងៗទៀត
	733		ការជួលទ្រព្យសម្បត្តិអចល័ត
74			**ផលពីការផាកពិន័យ និង ការដាក់ទណ្ឌកម្ម**
	741		ផលពីការផាកពិន័យ និង ការដាក់ទណ្ឌកម្ម
75			**ការឧបត្ថម្ភធន**
	751		ទាយជ្ជទានសំរាប់ដំណើរការដែលឧបត្ថម្ភដោយថវិកាខេត្ត ក្រុង
	752		ទាយជ្ជទានសំរាប់ដំណើរការដែលឧបត្ថម្ភដោយថវិការដ្ឋ
	758		ចំណូលឧបត្ថម្ភថវិកាពីប្រភពផ្សេងៗ
77			**ផលផ្សេងៗនិងផលពិសេស**
	775		ផលពីការលក់អចលកម្ម
			ខ_ក្រុមទី ២ : ចំណូលតាមដីកា (ប្រភេទទី៣)
			ប្រភេទទី ៣ : ចំណូលតាមដីកា (មិនឆ្លងកាត់សាច់ប្រាក់)
77			**ផលផ្សេងៗនិងផលពិសេស**
78			**ការងារនៃរដ្ឋទេយ្យ**
			II - សរុបចំណូលជាមូលធន
			ក_ក្រុមទី ១: ចំណូលពិត (ប្រភេទទី១ + ប្រភេទទី២)
			ប្រភេទទី ១: ឧបត្ថម្ភធន
13			**ឧបត្ថម្ភធនវិនិយោគ**

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណូល
	131		ឧបត្ថម្ភកធនទព្វសំភារៈបរិក្ខារទូរភាគី
ប្រភេទនី ២: ចំណូលតាមជីកា (មិនឆ្លងកាត់សាច់ប្រាក់)			
			....
			....
ខ-ក្រុមនី ២: ចំណូលតាមជីកា			
ប្រភេទនី ៣: ចំណូលតាមជីកា (មិនឆ្លងកាត់សាច់ប្រាក់)			

ឧបសម្ព័ន្ធ២

មាតិកាចំណាយថវិកាស្រុក-ខណ្ឌ

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ
			សរុបរួមចំណាយថវិកាស្រុក-ខណ្ឌ
			I - សរុបចំណាយចរន្ត
			ក.ផ្នែកទី ១ : ចំណាយពិត (ប្រភេទទី១ + ប្រភេទទី២ + ប្រភេទទី៣ + ប្រភេទទី៤)
			ប្រភេទទី ១ : ការទិញនិងសេវា
60			**ការទិញ**
	601		សំភារៈផ្គត់ផ្គង់ថែទាំ
		6011	សំភារៈផ្គត់ផ្គង់សំអាតនិងអនាម័យ
		6012	សំភារៈផ្គត់ផ្គង់សំរាប់ថែទាំអាគារ
		6013	សំភារៈផ្គត់ផ្គង់សំរាប់ថែទាំ ផ្លូវថ្នល់ ផ្លូវលំ ស្ពាន និងលូ
		6014	សំភារៈផ្គត់ផ្គង់សំរាប់ថែទាំសំភារៈឧបករណ៍
		6015	ប្រេងឥន្ធនៈនិងប្រេងរំអិល
	602		សំភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល
		6021	សំភារៈការិយាល័យនិងការបោះពុម្ព
		6022	សៀវភៅមើល និង ឯកសារ
		6028	ផ្សេងៗ
	603		ស្បៀងអាហារ
		6031	ស្បៀង
	604		សំលៀកបំពាក់និងការតុបតែង
		6041	ឯកសណ្ឋាន
		6042	សំលៀកបំពាក់ការពារសុវត្ថិភាព
		6043	មេដាយ(គ្រឿងឥស្សរិយយស)
		6048	ផ្សេងៗ
	605		សំភារៈតូចតាច សង្ហារឹម និងសំភារៈបរិក្ខារ
		6051	សំភារៈនិង បរិក្ខារ
		6052	សង្ហារឹម
		6053	សំភារៈប្រើប្រាស់
		6058	ផ្សេងៗ

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ
	606		ថាមពល និង ទឹក
		6061	អគ្គិសនី
		6062	ទឹក
		6068	ផ្សេងៗ
	608		សំភារៈផ្គត់ផ្គង់ផ្សេងៗ
61			**សេវាខាងក្រៅ**
	611		កិច្ចសន្យានៃការផ្តល់សេវាជាមួយសហគ្រាស
	612		ការជួលមធ្យោបាយដឹកជញ្ជូន
	613		ថ្លៃឈ្នួល និងបន្ទុក (អសង្ហារឹម)
	614		សោហ៊ុយបណ្តុះបណ្តាលបុគ្គលិក
	615		ការថែទាំ និងជួសជុល
		6151	ការថែទាំដីធ្លី សួនច្បារ,រៀបជាជួរ
		6152	ការថែទាំ ទីផ្សារ សត្តឃាតដ្ឋាន និងអាគារសាធារណៈ
		6153	ការថែទាំជួសជុលផ្លូវ ផ្លូវលំ ស្ពាន និងប្រពន្ធ័លូ
		6154	ការថែទាំបណ្តាញផ្សេងៗ
		6155	ការថែទាំ និងជួសជុលឧបករណ៍ សំភារៈការិយាល័យ សំភារៈពតិមានវិទ្យា និងទូរគមនាគមន៍
		6156	ការថែទាំ និងជួសជុលមធ្យោបាយដឹកជញ្ជូន
		6157	ការថែទាំ និងជួសជុលសំភារៈឧបករណ៍បច្ចេកទេស
	616		សោហ៊ុយធានារ៉ាប់រង
	617		សោហ៊ុយសិក្សាពិសោធន៍ សោហ៊ុយនៃការប្រើប្រាស់សេវានិង សោហ៊ុយនៃការប្រើប្រាស់សិទ្ធិ
		6171	សោហ៊ុយសិក្សាពិសោធន៍
		6172	សោហ៊ុយនៃការប្រើប្រាស់សេវា
		6173	សោហ៊ុយនៃការប្រើប្រាស់សិទ្ធិ
	618		សោហ៊ុយដឹកជញ្ជូន
		6181	សំភារៈ និងទំនិញ
62			**សេវាខាងក្រៅផ្សេងៗ**
	621		បុគ្គលិកខាងក្រៅ
		6211	ភ្នាក់ងារជាតិជាប់កិច្ចសន្យា
		6212	ភ្នាក់ងារបរទេសជាប់កិច្ចសន្យា
		6213	បុគ្គលិកសម្ភហភាពសាធារណៈផ្សេងៗ
	622		ទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយ
		6221	សោហ៊ុយទទួលភ្ញៀវជាតិ

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ
		6222	សោហ៊ុយទទួលភ្ញៀវបរទេស
		6223	ប្រជុំ -សិក្ខាសាលា និងសន្និសីទ
		6224	សោហ៊ុយពិធីបុណ្យ
			. បុណ្យជាតិ និងបុណ្យប្រពៃណីយ៍
			. បុណ្យចំរើនព្រះជន្មាយុព្រះមហាក្សត្រ
			.. បុណ្យរុក្ខទិវា
			. បុណ្យផ្សេងៗទៀត
		6225	ចំណាយសំរាប់វត្ថុអនុស្សាវរីយ៍ក្នុង និងក្រៅប្រទេស
		6226	សោហ៊ុយសំរាប់ការតាំងពិពណ៌នៅក្នុងនិងក្រៅប្រទេស
		6227	ការឃោសនានិងផ្សព្វផ្សាយពត៌មានសាធារណៈ
	623		សោហ៊ុយជាវសារពត៌មាន និងឯកសារ
	624		ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស
		6241	សោហ៊ុយដឹកជញ្ជូន
		6242	សោហ៊ុយបេសកកម្ម
		6243	សោហ៊ុយស្នាក់នៅ
	625		ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស
		6251	សោហ៊ុយដឹកជញ្ជូន
		6252	សោហ៊ុយបេសកកម្ម
		6253	សោហ៊ុយស្នាក់នៅ
	626		សោហ៊ុយទូរគមនាគមន៍ ទូរស័ព្ទតេឡិច និងទូរសារប្រៃសណីយ៍
		6261	សោហ៊ុយប្រៃសណីយ៍
		6262	សោហ៊ុយទូរគមនាគមន៍
	627		សោហ៊ុយធនាគារ
	628		សោហ៊ុយផ្សេងៗ
64			**បន្ទុកបុគ្គលិក**
	641		លាភការ និង ប្រាក់បំណាច់ នៃអំណាចសាធារណៈ
		6411	ប្រាក់បំណាច់អភិបាលស្រុក-ខណ្ឌ
		6412	ប្រាក់បំណាច់អភិបាលរងស្រុក-ខណ្ឌ
		6419	ការសង និងការបង្វិលវិញ
	642		លាភការនិងប្រាក់បំណាច់បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍
		6421	បៀវត្សមូលដ្ឋាន
			. ចំនួន

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ
			. ប្រភេទ
			. ខុទ្ទកាល័យ
		6422	ប្រាក់បំណាច់មុខងារ
		6423	ប្រាក់បំណាច់ម៉ោងបន្ថែម
		6424	ប្រាក់បំណាច់តំបន់
		6425	ប្រាក់បំណាច់ទទួលខុសត្រូវ
		6426	ប្រាក់បំណាច់ការងារធ្ងន់ និងប៉ះពាល់សុខភាព
		6429	ការសង និងការបង្វិលវិញ
	643		រង្វាន់ និងប្រាក់បំណាច់ផ្សេងៗទៀត
		6431	កន្សោមអធិភាព
		6432	ប្រាក់បំណាច់សំរាប់ប្រឡង-ប្រឡងប្រជែង
		6433	រង្វាន់
		6434	ប្រាក់បំណាច់បុគ្គលិកក្រសួងផ្សេងៗ
		6438	ផ្សេងៗ
		6439	ការសង និងការបង្វិលវិញ
	644		លាភការ និងប្រាក់បំណាច់បុគ្គលិកមិនមែនក្របខ័ណ្ឌ និងបុគ្គលិកអណ្តែត
		6441	ប្រៀវត្សមូលដ្ឋានបុគ្គលិកមិនមែនក្របខ័ណ្ឌ
		6442	លាភការផ្សេងៗទៀតបុគ្គលិកមិនមែនក្របខ័ណ្ឌ
		6443	ប្រៀវត្សមូលដ្ឋានបុគ្គលិកអណ្តែត
		6444	លាភការផ្សេងៗទៀតបុគ្គលិកអណ្តែត
		6449	ការសង និងការបង្វិលវិញ
	645		ប្រាក់វិភាជន៍សង្គម
		6451	ប្រាក់បំណាច់ជាលក្ខណៈគ្រួសារ
			. កូនមានអាយុតិចជាង១៥ ឆ្នាំ
			. កូនរៀនវិទ្យាល័យ អនុវិទ្យាល័យ
			. ប្រាក់បំណាច់អ្នកក្នុងបន្ទុក
		6452	មន្ត្រីមានជំងឺ និងឧបត្ថម្ភអ្នកសំរាលកូន
		6453	មរណៈភាព
		6454	ឧបត្ថម្ភនិវត្តជន
		6455	ឧបត្ថម្ភដល់អ្នកសុំឈប់ពីការងារ
		6456	គ្រោះថ្នាក់ការងារ និងទព្វលភាព
		6457	ឧបត្ថម្ភដល់កូនកំព្រារបស់មន្ត្រីរាជការ

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ
		6458	ផ្សេងៗ
		6459	ការសង និងការបង្វិលវិញ
			ប្រភេទទី ២ : បន្ទុកហិរញ្ញវត្ថុ
66			**បន្ទុកហិរញ្ញវត្ថុ**
			ប្រភេទទី ៣ : អន្តរាគមន៍សាធារណៈ
65			**ឧបត្ថម្ភធន និងជំនួយសង្គម**
	651		ឧបត្ថម្ភធនដល់រដ្ឋបាលដែនដី
		6511	ឧបត្ថម្ភធនដល់ឃុំ សង្កាត់
		6512	ឧបត្ថម្ភគ្រឹះស្ថានសាធារណៈរដ្ឋបាល
	652		ជំនួយសង្គមនិងប្រាក់វិភាជន៍
		6521	ជំនួយដល់ប្រជាជនក្រីក្រសំរាកពេទ្យ
		6522	ជួយជនរងគ្រោះដោយធម្មជាតិ
		6528	ចំណាយសង្គមផ្សេងៗទៀត
	653		ឧបត្ថម្ភធនដល់អង្គភាពមានលក្ខណៈសង្គមនិងវប្បធម៌
		6531	ឧបត្ថម្ភមណ្ឌលកុមារកំព្រា
		6532	ឧបត្ថម្ភសហគមន៍ កីឡា និងវប្បធម៌
		6533	ឧបត្ថមកាកបាទក្រហម
			ប្រភេទទី ៤ : ចំណាយផ្សេងៗ
63			**ពន្ធ និង អាករ**
	631		លតាប័ត្រ
			ខ.ក្រុមទី ២ : ចំណាយតាមដីកា និងចំណាយមិនបានគ្រោងទុក (ប្រភេទទី៥ + ប្រភេទទី៦)
			ប្រភេទទី ៥ : ចំណាយតាមដីកា (មិនគួរសោចំណាត់ថ្នាក់)
67			**បន្ទុកពិសេស**
	671		ឥណទេយ្យដែលទទួលស្គាល់តែទារមិនបាន
	675		តំលៃគណនេយ្យនៃចំណែកសកម្មបានលក់ (តំលៃនៅសល់)
68			**ទាយជ្ជទានអោយដល់រំលស់អចលកម្ម**
	681		ទាយជ្ជទានអោយដល់រំលស់អចលកម្មអរូបី
	682		ទាយជ្ជទានអោយដល់រំលស់អចលកម្មរូបី
			ប្រភេទទី ៦ : ចំណាយមិនបានគ្រោងទុក
09			**ចំណាយមិនបានគ្រោងទុក**
			II - សរុបចំណាយជាមូលធន
			ក.ក្រុមទី ១ : ចំណាយពិត (ប្រភេទទី១ + ប្រភេទទី២)

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ
			ប្រភេទទី ១ : អចលកម្ម
20			**អចលកម្មអរូបី**
	203		សោហ៊ុយសិក្សា ស្រាវជ្រាវ និង អភិវឌ្ឍន៍
	205		ប្រកាសនីយប័ត្រ,អាជ្ញាប័ណ្ណនិងសិទ្ធិប្រហាក់ប្រហែល
21			**អចលកម្មរូបី**
	211		ដីធ្លី និងធនធានធម្មជាតិ
	212		ការរៀបចំកែលំអរដីធ្លី
	213		សំណង់
		2131	អាគារ
		2132	ការរៀបចំកែលំអរអាគារ
		2138	សំណង់ផ្សេងៗទៀត
	214		ហេដ្ឋារចនាសម្ព័ន្ធ
		2141	បណ្តាញបង្ហូរទឹក និងអនាម័យ
		2142	បណ្តាញអគ្គិសនី
		2143	បណ្តាញធារាសាស្ត្រ
		2144	បណ្តាញផ្លូវថ្នល់
	215		ឋបនកម្មបច្ចេកទេស សំភារៈ និងហត្ថបករណ៍
		2151	ឋបនកម្មបច្ចេកទេស
		2152	សំភារៈ
		2153	គ្រឿងឧបករណ៍ (ហត្ថបករណ៍)
	218		អចលកម្មរូបីយ៍ផ្សេងទៀត
		2181	សំភារៈឧបករណ៍ដឹកជញ្ជូន
		2182	សំភារៈឧបករណ៍ការិយាល័យ
		2183	សំភារៈពត៌មានវិទ្យា និងទូរគមនាគមន៍
		2184	សង្ហារឹម
		2188	ផ្សេងៗ
			ខ-ក្រុមទី ២ : ចំណាយតាមជីភា
			ប្រភេទទី ២ : ចំណាយតាមជីភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
Nº ១០៩ ឧរម.កឧ.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៧

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៥៧៣៦/០៦ គ.វ.ក ចុះថ្ងៃទី ២៥.១២.២០០៦ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន វីនតាយ (ខេមបូឌា) ហ្គាមេន ចុះថ្ងៃទី២០.១២.២០០៦

សម្រេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន វីនតាយ (ខេមបូឌា) ហ្គាមេន (WINTAI (CAMBODIA) GARMENT LTD.) តំណាងដោយ លោក LEE YIM FAI សញ្ជាតិអង់គ្លេស អាយុ៣៨ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 790113127 ចុះថ្ងៃទី៣១.០៣.២០០៦ បង្កើតរោងចក្រ "កាត់ដេរ និងចាក់សម្លៀកបំពាក់ មួក ស្រោមជើង ស្រោមដៃ និងកន្សែង" ដែលមានឈ្មោះថា "វីនតាយ (ខេមបូឌា) ហ្គាមេន (WINTAI (CAMBODIA) GARMENT)" មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ២ ភូមិឃ្លាំងសម្បត្តិ ឃុំតសរ ស្រុកបាទី ខេត្តតាកែវ ។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Blvd, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងមកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឱ្យបានមុនរយៈពេល ១៥ថ្ងៃ និងត្រូវផ្តល់ប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ក្នុងរយៈពេល ២ខែ យ៉ាងយូរ ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ " កាត់ដេរ និងចាក់សម្លៀកបំពាក់ មួក ស្រោមជើង-ស្រោមដៃ និងកន្សែង " ហើយត្រូវផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្ម របស់រោងចក្រ តាមមាត្រា ១៩ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តតាកែវ និងប្រធានក្រុមហ៊ុន វីនតាយ (ខេមបូឌា) ហ្គាមេន ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ_សែម

ចម្លងជូន:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលាខេត្តតាកែវ

" ដើម្បីជូនជ្រាប "
- ដូចប្រការ ៩ " ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ១១១-រ៉ែ.ឧរ.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៧

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ០១២/០៧ ត.រ.ក ចុះថ្ងៃទី០៣.០១.២០០៧ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន សាង មីន (ខេមបូឌា) ខូអិលធីឌី ចុះថ្ងៃទី១៥.១២.២០០៦

សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន សាង មីន (ខេមបូឌា) ខូអិលធីឌី (SANG MIN (CAMBODIA) CO., LTD.) តំណាងដោយ លោក KIM KWANG SIK សញ្ជាតិកូរ៉េ អាយុ៤៦ឆ្នាំ កាន់លិខិតឆ្លងដែនលេខ YP1661547 ចុះថ្ងៃទី ០៤.១២.២០០៤ បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា " សាង មីន (ខេមបូឌា) ខូអិលធីឌី (SANG MIN (CAMBODIA) CO., LTD.)" មានទីតាំងស្ថិតនៅ សួនឧស្សាហកម្មកាណាឌីយ៉ា អាគារលេខ៣៥ ភូមិត្រពាំងថ្លឹង ផ្លូវវែងស្រេង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: មុនចាប់ផ្តើមដំណើរការរោងចក្រ ក្រុមហ៊ុនត្រូវជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ឱ្យបានមុនរយៈពេល១៥ថ្ងៃ និងត្រូវរៀបចំរោងចក្រ ទៅតាមប្លង់ដែលបានតម្កល់ទុកនៅ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះ ត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់" ហើយត្រូវផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្ម របស់រោងចក្រ តាមមាត្រា១៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម ជូន ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន សាង មីន (ខេមបូឌា) ខូអិលធីឌី ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះ មានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ស៊ុយ_សែម

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាក្រុងភ្នំពេញ
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៩ " ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ១១២ ឧរម.ករ-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែ មករា ឆ្នាំ ២០០៧

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៤៥៧៨/០៦ ត.វ.ក ចុះថ្ងៃទី ២៥.១២.២០០៦ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ប្ល៊ូសសាម សេនជូរី (ខេមបូឌា) ចុះថ្ងៃទី២០.១២.២០០៦

សម្រេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន ប្ល៊ូសសាម សេនជូរី (ខេមបូឌា) (BLOSSOM CENTURY (CAMBODIA) LTD.) តំណាងដោយ លោក LEE CHING KIN សញ្ជាតិចិន (ហុងកុង) អាយុ៣២ឆ្នាំ កាន់លិខិតឆ្លងដែនលេខ H90095608 ចុះថ្ងៃទី១៨.១២.២០០០ បង្កើតរោងចក្រ "កាត់ដេរ និង ចាក់សម្លៀកបំពាក់ មួក ស្រោមជើង_ស្រោមដៃ និងកន្សែង" ដែលមានឈ្មោះថា "ប្ល៊ូសសាម សេនជូរី (ខេមបូឌា) (BLOSSOM CENTURY (CAMBODIA))" មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ២ ភូមិឃ្លាំងសម្បត្តិ ឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ ។

៤៥ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

__ប្រការ២:__ មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងមក ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ឱ្យបាន មុនរយៈពេល ១៥ថ្ងៃ និងត្រូវផ្តល់ប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ក្នុងរយៈពេល ២ខែ យ៉ាងយូរ ។

__ប្រការ៣:__ រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ " កាត់ដេរ និងចាក់សម្លៀកបំពាក់ មួក ស្រោមជើង-ស្រោមដៃ និង កន្សែង " ហើយត្រូវផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែ អំពី ស្ថានភាពផលិតកម្ម របស់រោងចក្រ តាមមាត្រា ១៥ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

__ប្រការ៤:__ ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរ ផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

__ប្រការ៥:__ ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវ សុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

__ប្រការ៦:__ ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

__ប្រការ៧:__ ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្ត ប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

__ប្រការ៨:__ ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសចំពោះប្រការ ណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

__ប្រការ៩:__ អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តតាកែវ និងប្រធានក្រុមហ៊ុន ប៊ួសសាម សេនជូរី (ខេមបូឌា) ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

__ប្រការ១០:__ ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

__ចម្លងជូន :__
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលាខេត្តតាកែវ

" ដើម្បីជូនជ្រាប ".
- ដូចប្រការ ៩ " ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
Nº ១៦៤ ឧរម.កឧ-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៧

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញប្រកាសលេខ៧៦ ផក.ប្រក ចុះថ្ងៃទី ១៧.០១.១៩៩៤ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- យោងពាក្យស្នើរបស់ក្រុមហ៊ុន រោងចក្របារីកម្ពុជា ចុះថ្ងៃទី២៥.១២.២០០៦

សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន រោងចក្របារីកម្ពុជា (USINE DES TABACS DU CAMBODGE) តំណាងដោយលោក ហួត វ៉ាន់ថន សញ្ជាតិខ្មែរ អាយុ៦៦ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណលេខ ០១០៤៦៤៦៤៥ ចុះថ្ងៃទី ០៦.០៨.២០០៣ បង្កើតរោងចក្រ “ផលិតបារី” ដែលមានឈ្មោះថា “ រោងចក្រ បារី កម្ពុជា (USINE DES TABACS DU CAMBODGE) ” មានទីតាំងស្ថិតនៅ ផ្លូវលេខ២០៦ ភូមិដើមមៀន, ឃុំដើមមៀន ស្រុកតាខ្មៅ ខេត្តកណ្តាល ។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23.428263

ប្រការ២: មុនចាប់ផ្តើមដំណើរការរោងចក្រ ក្រុមហ៊ុនត្រូវជូនដំណឹងមកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ឱ្យបានមុនរយៈពេល១៥ថ្ងៃ និង ត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតម្កល់ទុកនៅ ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "ផលិតបារី " ហើយត្រូវផ្តល់ទិន្នន័យនិងរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្ម របស់រោងចក្រ តាមមាត្រា១៥នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសរសេរអក្សរ "ជក់បារីនាំឱ្យខូចសុខភាព " នៅលើកញ្ចប់បារី មុននឹងចរាចរផលិតផលរបស់ខ្លួនលើទីផ្សារ ។

ប្រការ៨: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៩: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសចំពោះចំនួនប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ១០: ប្រកាសលេខ ៧៦ ឧក.ប្រក ចុះថ្ងៃទី១៧.០១.១៩៩៤ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ស្តីពីការបង្កើតរោងចក្រ ផលិតបារី របស់ក្រុមហ៊ុន " រោងចក្របារីកម្ពុជា " (Usine des Tabacs du Cambodge) ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ១១: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកណ្តាល និង ប្រធានក្រុមហ៊ុន រោងចក្របារីកម្ពុជា ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១២: ប្រកាសនេះមានអនុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ_សែម

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលាខេត្តកណ្តាល
  " ដើម្បីជូនជ្រាប "
- ដូចប្រការ ១១ " ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
Nº ១៦៥ រ.ប.ក.ឧ.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែ មករា ឆ្នាំ ២០០៧

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៤៦១១/០៦ គ.វ.ក ចុះថ្ងៃទី២៧.១២.២០០៦ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន រីវើរ ខប ចុះថ្ងៃទី២៧.១១.២០០៦

សម្រេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន រីវើរ ខប (RIVER CORP.) តំណាងដោយ លោក KOBAYASHI MASUJI សញ្ជាតិ ជប៉ុន អាយុ៦០ឆ្នាំ កាន់លិខិតឆ្លងដែនលេខ TZ0444087 ចុះថ្ងៃទី ០៦.០៩.២០០៦ បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា "រីវើរ ខប (RIVER CORP.)" មានទីតាំងស្ថិតនៅ ភូមិតាងួន សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣.២១១១៤១ , ទូរសារ : ៨៥៥.២៣.៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855.23.211141 , Fax : 855.23 428263

ប្រការ២: មុនចាប់ផ្តើមដំណើរការរោងចក្រ ក្រុមហ៊ុនត្រូវជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ឱ្យបានមុនរយៈពេល១៥ថ្ងៃ និងត្រូវផ្តល់ប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ក្នុងរយៈពេល ២ខែយ៉ាងយូ ។

ប្រការ៣: រោងចក្រនេះ ត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសម្លៀកបំពាក់" ហើយត្រូវផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្ម របស់រោងចក្រ តាមមាត្រា១៥ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់១ឆ្នាំក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន វីវើរ ខប ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀង១ខ្លួន ។

ប្រការ១០: ប្រកាសនេះ មានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាក្រុងភ្នំពេញ
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៩ " ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខៈ ៧៤១៧ ......អយក.ប្រក

លិខិតចូល

ថ្ងៃទី ៣០ ខែ មករា ឆ្នាំ 2007

ប្រកាស

ស្តីពី

ការបង្កើតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា

****

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញលិខិតលេខ ៤២១ សជណ.អរ ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ១៩៩៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីករណីសុំប្តូរឈ្មោះវិទ្យាស្ថានបច្ចេកវិទ្យាភ្នំពេញ ជាវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា
- បានឃើញប្រកាសលេខ ១០៤៩ អយក.ប្រក ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៣ របស់ក្រសួងអប់រំ យុវជន និងកីឡាស្តីពីការបណ្តុះបណ្តាលថ្នាក់អនុបណ្ឌិត
- បានឃើញប្រកាសលេខ ៧០៦ អយក.ប្រក ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៤ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការបំពេញបន្ថែមលើប្រកាសលេខ ១០៤៩ អយក.ប្រក ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៣ ស្តីពីការបណ្តុះបណ្តាលថ្នាក់អនុបណ្ឌិត
- បានឃើញសារាចរណែនាំលេខ ០៦ អយក.សរណន ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០០២ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការបើកឯកទេសថ្មី ដេប៉ាតឺម៉ង់ថ្មី មហាវិទ្យាល័យថ្មី និងការបើកសាខានៅតាមគ្រឹះស្ថានឧត្តមសិក្សា
- បានឃើញលិខិតលេខ ៤២១ វបក ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០៦ របស់វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា
- បានឃើញយោបល់របស់អគ្គនាយកដ្ឋានឧត្តមសិក្សា។

ស ម្រេ ច

ប្រការ ១.-

អនុញ្ញាតឱ្យ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា បើកថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ លើមុខជំនាញដូចខាងក្រោម ៖

- ទេពកោសល្យអគ្គិសនី និងថាមពល
- ទេពកោសល្យព័ត៌មានវិទ្យា និងទូរគមនាគមន៍
- ទេពកោសល្យជនបទ
- ទេពកោសល្យឧស្សាហកម្ម និងមេកានិច
- ទេពកោសល្យគីមីចំណីអាហារ និងវិស្វកម្មគីមី
- ទេពកោសល្យសំណង់ស៊ីវិល ។

ប្រការ ២.-

លក្ខខណ្ឌជ្រើសរើសនិស្សិតឱ្យចូលរៀន ត្រូវគោរពតាមបទដ្ឋាន កំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា ។

ប្រការ ៣.-

និស្សិតដែលរៀនចប់កម្មវិធីសិក្សា ហើយបានទទួលជោគជ័យក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួល បានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់តាមមុខជំនាញ ដែលបានសិក្សា ។ សញ្ញាបត្រនេះ ផ្តល់ឱ្យដោយ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា នឹងត្រូវបានទទួលស្គាល់ ពីក្រសួងអប់រំ យុវជន និងកីឡា ។

ប្រការ ៤.-

អគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នាយកដ្ឋានឧត្តមសិក្សា នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ និងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា មានភារកិច្ច រៀងៗខ្លួន អនុវត្ត និងប្រតិបត្តិតាមប្រកាសនេះ ។

ប្រការ ៥.-

ប្រកាសនេះមានប្រសិទ្ធភាព គតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ... ឆ្នាំ ២០០៦

បណ្ឌិត គឹម សេង

កន្លែងទទួល ៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់អង្គភាពក្រោមឱវាទក្រសួង.អយក
- គ្រប់គ្រឹះស្ថានឧត្តមសិក្សា
  " ដើម្បីជ្រាបជាព័ត៌មាន "
- ដូចក្នុងប្រការ ៦ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ -ឯកសារ នា.ឧស

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខៈ ៧៤៧៤ អយក.ប្រក

លិខិតចូល
ថ្ងៃទី៣០ ខែមករា ឆ្នាំ2007

ប្រកាស

ស្តីពី

ការរៀបចំ និងការប្រព្រឹត្តទៅ នៃការប្រឡងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ

<u>ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា</u>

- បានឃើញព្រះរាជក្រឹត្យលេខនស.រកត.០៧០៤-១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី។
- បានឃើញព្រះរាជក្រមលេខ នស/-កម ០១៩៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា។
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ ខែ មីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា។
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.០៧៩៦.៩២ ចុះថ្ងៃទី២៦ កក្កដា ១៩៩៦ ស្តីអំពីប្រព័ន្ធអប់រំចំណេះទូទៅ១២ឆ្នាំ។
- បានឃើញលិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រី លេខ១៨៥២ សជណ.អវ.ចុះថ្ងៃទី២៣ ធ្នូ ១៩៩៩ ស្តីពីការលុបប្រឡងសញ្ញាប័ត្រមធ្យមសិក្សាលើកទី២។
- យោងតាមការចាំបាច់របស់ ក្រសួងអប់រំ យុវជន និងកីឡា។

សម្រេច

ប្រការ ១ -មណ្ឌលប្រឡងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ត្រូវកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា រៀងរាល់ឆ្នាំសិក្សា។

ប្រការ ២ - ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង និងនាយកគ្រឹះស្ថានសិក្សាដែលគ្រឹះស្ថានត្រូវបានកំណត់ជាមណ្ឌលប្រឡង មានភារៈរៀបចំបន្ទប់ប្រឡង និងសំភារៈចាំបាច់សំរាប់ការប្រព្រឹត្តទៅនៃការប្រឡងឱ្យហើយស្រេច មុនបើកសម័យប្រឡង។

ប្រការ ៣- មណ្ឌលប្រឡងនីមួយៗ ត្រូវមានប្រធាន អនុប្រធាន និងសមាជិកមេប្រយោគមួយចំនួនតាមការចាំបាច់នៃមណ្ឌលប្រឡង។

ប្រការ ៤ - សមាសភាព និងចំនួនព្រមទាំងលិខិតឧទ្ទេសនាមមេប្រយោគ ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា តាមសំណើរបស់ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ តាមឋានានុក្រម។

ប្រការ៥ - បន្ទប់ប្រឡងនីមួយៗ ត្រូវដាក់បេក្ខជនត្រឹម២៥ «ម្ភៃប្រាំ» នាក់។ បើមានបេក្ខជននៅសល់ ត្រូវដាក់ក្នុងបន្ទប់មួយដោយឡែក។

ប្រការ៦ - ប្រធានមណ្ឌលនៃមណ្ឌលសំណេរនីមួយៗ ជាអ្នកទទួលខុសត្រូវរួម ក្នុងការដំណើរការប្រព្រឹត្តទៅនៃដំណើរការវិញ្ញាសាសរសេរទាំងផ្នែករដ្ឋបាល ទាំងផ្នែកបច្ចេកទេសចំពោះមុខក្រសួងអប់រំ យុវជន និងកីឡា។

ប្រការ៧ - ប្រធានមណ្ឌល ត្រូវសហការ ឬធ្វើអន្តរាគមន៍ដល់អាជ្ញាធរមានសមត្ថកិច្ចនានាក្នុងខេត្ត-ក្រុងនៃមណ្ឌលប្រឡង ក្នុងករណីចាំបាច់ ដើម្បីរក្សារបៀបរៀបរយក្នុងពេលប្រឡង។

ប្រការ៨ - មណ្ឌល ឬអនុមណ្ឌលប្រឡងណាមួយដែលមិនមានភាពប្រក្រតីតាមលក្ខការណ៍ នៃការប្រឡង ប្រធានមណ្ឌលនៃមណ្ឌល ឬអនុមណ្ឌលនោះត្រូវរាយការណ៍ជាបន្ទាន់មក គណៈមេប្រយោគទូទាំងប្រទេស និងអាជ្ញាធរដែនដីដើម្បីដោះស្រាយ ឬសុំការសម្រេចពីក្រសួងអប់រំ យុវជន និងកីឡា។

ប្រការ៩ - ប្រធានមណ្ឌល ត្រូវបែងចែកភារកិច្ចដល់អនុប្រធាន និងសមាជិកមេប្រយោគឱ្យទទួលខុសត្រូវតាមមុខងាររៀងៗខ្លួន។

ប្រការ១០- ភារកិច្ចគណៈកម្មការ អនុគណៈកម្មការ និងសមាជិកមេប្រយោគ នឹងមានចែងក្នុងកម្រងភារកិច្ចគណៈមេប្រយោគ។

ប្រការ១១- នឹងអនុញ្ញាតឱ្យចុះឈ្មោះប្រឡងបាន សិស្សថ្នាក់ទី១២ នៃវិទ្យាល័យសាធារណៈ និងឯកជនដែលបានរៀននៅមធ្យមសិក្សាទុតិយភូមិគ្រប់កំរិតថ្នាក់ បានរៀនចប់កម្មវិធីសិក្សាថ្នាក់ទី១២ មានសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ និងគោរពបានត្រឹមត្រូវបទបញ្ជាផ្ទៃក្នុងសម្រាប់គ្រឹះស្ថានមធ្យមសិក្សា ហើយត្រូវបានវាយតំលៃផ្នែកសីលធម៌រស់នៅប្រចាំឆ្នាំចាប់ពីមធ្យមឡើងទៅ។ ពាក្យសុំចុះឈ្មោះប្រឡងមានបិទតែម ត្រូវស្នើសុំទៅរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាតាមឋានានុក្រម។

ប្រការ១២- អាចសុំចុះឈ្មោះប្រឡងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ជាបេក្ខជនស្វ័យរិនបាន អតីតបេក្ខជនដែលបានប្រឡងធ្លាក់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ។

ប្រការ១៣- បេក្ខជន ត្រូវភ្ជាប់នឹងពាក្យសុំប្រឡងរបស់ខ្លួននូវ ÷

- វិញ្ញាបនប័ត្របណ្តោះអាសន្នមធ្យមសិក្សាបឋមភូមិ ១សន្លឹក
- បង្កាន់ដៃបង់សិទ្ធិប្រឡង ១ច្បាប់។
- សៀវភៅសិក្ខាគារិក «ចំពោះសិស្សសាលាឯកជន»។

ប្រការ ១៤-ពាក្យសុំចុះឈ្មោះប្រឡង នឹងត្រូវប្រមូលផ្តុំតាមគ្រឹះស្ថានសិក្សាដែលខ្លួនសិក្សា។ នាយកគ្រឹះស្ថានសិក្សាត្រូវប្រមូលសំណុំលិខិតរបស់បេក្ខជន បញ្ជូនទៅនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅតាមរយៈមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង ដើម្បីធ្វើការបែងចែកនាមត្រកូលបេក្ខជនតាម

លំដាប់អក្ខរក្រម (លំដាប់ ព្យញ្ជនៈ និង ស្រៈ) ទៅតាមបន្ទប់ប្រឡង។

ប្រការ ១៥- បេក្ខជនស្វ័យរិន ត្រូវដាក់ពាក្យសុំប្រឡង ដោយមានបញ្ជាក់សម័យប្រឡង មណ្ឌលប្រឡង លេខបន្ទប់ លេខតុ នៃសម័យប្រឡងមុន នៅតាមមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុងដែលសាមីខ្លួនបានសុំប្រឡងពីមុន ឬនៅនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ។

ប្រការ ១៦- មន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុងត្រូវធ្វើបញ្ជីរាយនាមបេក្ខជន ផ្ញើទៅក្រសួងអប់រំ យុវជននិងកីឡា «នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ» ដើម្បីពិនិត្យសម្រេចលើបេក្ខភាព។

ប្រការ ១៧- បេក្ខជនត្រូវអនុវត្តតាមបទបញ្ញត្តិទូទៅនៃការប្រឡង ដែលមានចែងក្នុងអត្ថបទមួយដោយឡែក។

ប្រការ ១៨- វិញ្ញាសា ថេររវេលា និងពិន្ទុនៃការប្រឡងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ នឹងត្រូវបានកំណត់ដូចតទៅ ÷

១- ភាសាខ្មែរ	រយៈពេល ១២០នាទី	ត្រូវបានពិន្ទុពី ០ ដល់ ១០០
២- គណិតវិទ្យា	រយៈពេល ១៥០នាទី	ត្រូវបានពិន្ទុពី ០ ដល់ ១២៥
៣- រូបវិទ្យា	រយៈពេល ៩០នាទី	ត្រូវបានពិន្ទុពី ០ ដល់ ៧៥
៤- គីមី	រយៈពេល ៦០នាទី	ត្រូវបានពិន្ទុពី ០ ដល់ ៥០
៥- ជីវវិទ្យា	រយៈពេល ៦០នាទី	ត្រូវបានពិន្ទុពី ០ ដល់ ៥០
៦- ផែនដីវិទ្យា	រយៈពេល ៣០នាទី	ត្រូវបានពិន្ទុពី ០ ដល់ ២៥
៧- ប្រវត្តិវិទ្យា	រយៈពេល ៤៥នាទី	ត្រូវបានពិន្ទុពី ០ ដល់ ៣៧
៨- ភូមិវិទ្យា	រយៈពេល ៤៥នាទី	ត្រូវបានពិន្ទុពី ០ ដល់ ៣៨
៩- សីលធម៌-ពលរដ្ឋវិជ្ជា	រយៈពេល ៦០នាទី	ត្រូវបានពិន្ទុពី ០ ដល់ ៥០
១០- ភាសាបរទេស	រយៈពេល ៦០នាទី	ត្រូវបានពិន្ទុពី ០ ដល់ ៥០

វិញ្ញាសានីមួយៗនឹងត្រូវបានពិន្ទុសូន្យចំពោះបេក្ខជនអវត្តមាន ឬបេក្ខជនដែលមិនបានប្រគល់សន្លឹកកិច្ចការដល់គណៈមេប្រយោគ លើកលែងតែវិញ្ញាសាភាសាបរទេស ដែលជាវិញ្ញាសាតាមស្ម័គ្រ។

ប្រការ ១៩- បេក្ខជនទាំងឡាយ អាចជ្រើសរើសយកភាសាតែមួយប៉ុណ្ណោះ ក្នុងចំណោមភាសាបារាំង ឬភាសាអង់គ្លេស នៅពេលធ្វើ វិញ្ញាសាភាសាបរទេស។

ប្រការ ២០- ពិន្ទុភាសាបរទេសនឹងគិតយកតែពិន្ទុដែលបេក្ខជនធ្វើបានលើសពី២៥ ទៅបូកបញ្ចូលជាមួយពិន្ទុមុខវិជ្ជាផ្សេងៗទៀត។

ប្រការ ២១- ប្រធានវិញ្ញាសាប្រឡង ត្រូវយកតាមកម្មវិធីសិក្សាថ្នាក់ទី១២ នៃមធ្យមសិក្សាទុតិយភូមិ។ វិញ្ញាសាទាំងឡាយជាវិញ្ញាសាសរសេរទាំងអស់។

ប្រការ ២២- ចំពោះសិស្សពិការភ្នែក អនុរក្ស ត្រូវអានប្រធានវិញ្ញាសា ឱ្យបេក្ខជនស្តាប់ ឬកត់ត្រា ដើម្បីធ្វើចម្លើយ ហើយត្រូវទូទាត់រយៈពេលហៅប្រធានវិញ្ញាសា តែមិនឱ្យប៉ះពាល់ដល់ការប្រព្រឹត្តទៅ នៃវិញ្ញាសាបន្ទាប់។ គណៈមេប្រយោគទូទាំងប្រទេសប្រចាំមណ្ឌលសំណេរ ត្រូវសំរេចដកសំណួរណា ដែលពាក់ព័ន្ធនឹងគំនូរ។

ប្រការ ២៣- ប្រធានវិញ្ញាសាទាំងឡាយត្រូវជ្រើសរើស ឬ តាក់តែងដោយក្រសួងអប់រំ យុវជន និងកីឡា។

ប្រការ ២៤- ប្រធានវិញ្ញាសាទាំងឡាយ ដែលបានជ្រើសរើសរួចហើយ ត្រូវដាក់ក្នុងស្រោមសម្ងាត់បិទជិត និងប្រថាប់ត្រា ហើយត្រូវបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចដែលមានមណ្ឌលប្រឡង តាមរយៈមេប្រយោគទូទាំងប្រទេសឱ្យថែរក្សាទុកយ៉ាងតិច៣៦ម៉ោង មុនពេលប្រកាសចាប់ផ្តើមប្រឡង។

ប្រការ ២៥- អាជ្ញាធរមានសមត្ថកិច្ច ដែលថែរក្សាវិញ្ញាសាទាំងនោះ ត្រូវប្រគល់ឱ្យគណៈមេប្រយោគទូទាំងប្រទេសនៅថ្ងៃចាប់ផ្តើមការប្រឡងមួយម៉ោង មុនពេលបើកសម័យប្រឡង។

ប្រការ ២៦- ការប្រគល់ឱ្យ និងការទទួលយកវិញ នូវប្រធានវិញ្ញាសាប្រឡងត្រូវមានការទទួលខុសត្រូវទាំងសងខាង ដោយមានកំណត់ហេតុជាផ្លូវការផង។

ប្រការ ២៧- វិញ្ញាសានីមួយៗ ត្រូវមានចំនួនសន្លឹកវិញ្ញាសា ស្មើនឹងចំនួនបេក្ខជន។ បើខ្វះត្រូវចម្លងបន្ថែមបង្គ្រប់ភ្លាម។

ប្រការ ២៨-កិច្ចការបេក្ខជនពិការភ្នែក ត្រូវធ្វើកំណែពិសេស ទៅតាមអត្រាកំណែដោយឡែក ដោយគ្រូបង្រៀនសិស្សពិការភ្នែក។

ប្រការ ២៩- ដំណើរការកំណែត្រូវប្រព្រឹត្តទៅនៅមណ្ឌលកំណែប្រមូលផ្តុំនៅរាជធានីភ្នំពេញ។

ប្រការ ៣០- មណ្ឌលកំណែត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មការមណ្ឌលកំណែដឹកនាំដោយប្រធានមួយនាក់។ ប្រធានមណ្ឌលកំណែត្រូវបានជ្រើសរើស ក្នុងចំណោមគណៈមេប្រយោគទូទាំងប្រទេស។

ប្រការ ៣១-បន្ទាប់ពីបញ្ចប់ដំណើរការវិញ្ញាសាសរសេរ មេប្រយោគទូទាំងប្រទេសប្រចាំខេត្ត-ក្រុង នីមួយៗ និងប្រធានមណ្ឌលនៃមណ្ឌលសំណេរនីមួយៗ ត្រូវប្រមូលកិច្ចការបេក្ខជន និងកំណត់ហេតុដំណើរការវិញ្ញាសាសរសេរមកប្រគល់ឱ្យប្រធានមណ្ឌលកំណែ។

ប្រការ ៣២- ប្រធាន-អនុប្រធានមណ្ឌលសំណេរនីមួយៗ ត្រូវចូលរួមបន្តការងារនៅមណ្ឌលកំណែ និងអនុវត្តភារកិច្ចតាមការចាត់តាំងរបស់ប្រធានមណ្ឌលកំណែ។

ប្រការ ៣៣- មណ្ឌលកំណែនីមួយៗត្រូវបែងចែកជាក្រុមមណ្ឌលមុខវិជ្ជា។

ប្រការ ៣៤- ប្រធាន-អនុប្រធានក្រុមមណ្ឌលមុខវិជ្ជាជ្រើសរើសក្នុងចំណោមគណៈមេប្រយោគទូទាំងប្រទេស ហើយចាំបាច់ត្រូវចុះអក្សរសម្ងាត់លើសន្លឹកកិច្ចការបេក្ខជន។

ប្រការ ៣៥- ពេលចប់កិច្ចការកំណែគ្រប់គណៈកម្មការនានាត្រូវ រំសាយ។ ត្រូវបង្កើតគណៈកម្មការថ្មីមួយសំរាប់ស្រង់បូកពិន្ទុដោយកុំព្យូទ័រ និងគណៈកម្មការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផល។

ប្រការ ៣៦- ការស្រង់បូកពិន្ទុដោយកុំព្យូទ័រ ប្រព្រឹត្តទៅនៅការិយាល័យប្រឡង នៃនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ។

ប្រការ ៣៧-កិច្ចការបេក្ខជននីមួយៗ ត្រូវកែដោយសមាជិកកំណែពីរនាក់ដាច់ដោយឡែក តាមតារាងអត្រាកំណែដែលគណៈមេប្រយោគបានសម្រេច។

ប្រការ ៣៨- ពិន្ទុសរុបនៃពិន្ទុប្រឡងគ្រប់មុខវិជ្ជា ហៅថាពិន្ទុប្រឡងថ្នាក់ជាតិ ជាពិន្ទុលើ ៥៧៥ ។

ប្រការ ៣៩- ពិន្ទុប្រចាំឆ្នាំស្មើនឹងមធ្យមភាគពិន្ទុឆមាសទី១ បូកនឹងមធ្យមភាគពិន្ទុឆមាសទី២ ជាពិន្ទុលើ ១០០។

ប្រការ ៤០- ពិន្ទុប្រចាំឆ្នាំតាមមុខវិជ្ជា ត្រូវធ្វើកំណែតម្រូវជាមួយពិន្ទុប្រឡងតាមមុខវិជ្ជា ហៅថា «ពិន្ទុប្រចាំឆ្នាំកំណែតម្រូវ »។

ប្រការ ៤១- ពិន្ទុប្រឡងស្មើនឹងពិន្ទុប្រចាំឆ្នាំកំណែតម្រូវ បូកនឹងពិន្ទុប្រឡងថ្នាក់ជាតិ។

ប្រការ ៤២- នឹងត្រូវប្រកាសថាប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ បេក្ខជននៃវិទ្យាល័យសាធារណៈ និងឯកជនទាំងឡាយណាដែលបានពិន្ទុប្រឡងចាប់ពី៣២៥ឡើងទៅ និងបេក្ខជនស្វ័យវិនទាំងឡាយណាដែលបានពិន្ទុប្រឡងថ្នាក់ជាតិចាប់ពី២៧៥ឡើងទៅ ដោយឥតមានពិន្ទុសូន្យចំពោះវិញ្ញាសាណាមួយ លើកលែងតែមុខវិជ្ជាភាសាបរទេស។

ក្នុងករណីចាំបាច់ អាចធ្វើសម្រង់ឱ្យជាប់បន្ថែម ក្រោយពីមានការយល់ព្រមពី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាតាមភាពជាក់ស្តែង និងតាមសំណើរបស់គណៈកម្មការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផល។ បេក្ខជនស្វ័យវិនមិនធ្វើសម្រង់ឱ្យជាប់បន្ថែមឡើយ។

ប្រការ ៤៣- អគ្គនាយកអប់រំ មានភារកិច្ចចុះហត្ថលេខាលើតារាងស្រង់ពិន្ទុ និងបញ្ជីចុះជាប់ធ្លាក់សម្រាប់បិទផ្សាយ។

ប្រការ ៤៤- និទ្ទេសនៃលទ្ធផលប្រឡងសម្រាប់ពិន្ទុសរុប និងពិន្ទុតាមមុខវិជ្ជា ត្រូវបានកំណត់ទៅតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា តាមសំណើរបស់ប្រធានគណៈមេប្រយោគទូទាំងប្រទេស។

ប្រការ ៤៥- បទបញ្ញត្តិ ស្តីពីការរៀបចំប្រឡងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ពីមុនៗទាំងឡាយណាដែលផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករណ៍។

ប្រការ ៤៦- អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកអប់រំ និងប្រធានអង្គភាពពាក់ព័ន្ធ នៃក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តតាមភារកិច្ចរៀងៗខ្លួន ដើម្បីឱ្យបានសម្រេចនូវប្រកាសនេះ។

ភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០០៦
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិត កុល ផេង

ចម្លងជូន :

- ទីស្តីការគណៈរដ្ឋមន្ត្រី
  «ដើម្បីសូមជ្រាបជាពត៌មាន»
- គ្រប់សាលាខេត្ត-ក្រុង
- គ្រប់អង្គភាពនៃក្រសួងអប់រំ យុវជន និងកីឡា
  «ដើម្បីជ្រាបជាពត៌មាន និង ជួយសហការ»
- មន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង
  «ដើម្បីអនុវត្ត»
- កាលប្បវត្តិ
- ឯកសារ-ធា.មចទ.

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខៈ ២៤៧៩ អយក.ប្រក

លិខិតចូល
ថ្ងៃទី ៣០ ខែ មករា ឆ្នាំ 2007

ប្រកាស

ស្តីពី

ការរៀបចំ និងការប្រព្រឹត្តទៅ នៃ ការប្រឡងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ

<u>ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា</u>

- បានឃើញព្រះរាជក្រឹត្យលេខនស.រកត.០៧០៤-១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី។
- បានឃើញព្រះរាជក្រមលេខ នសរ-កម ០១៩៦-០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា។
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ ខែ មីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា។
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.០៧៩៦.៥២ ចុះថ្ងៃទី២៦ កក្កដា ១៩៩៦ ស្តីអំពីប្រព័ន្ធអប់រំចំណេះទូទៅ១២ឆ្នាំ។
- បានឃើញលិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រី លេខ១៨៥២ សជណ.អរ.ចុះថ្ងៃទី២៣ ធ្នូ ១៩៩៩ ស្តីពីការលុបប្រឡងសញ្ញាប័ត្រមធ្យមសិក្សាលើកទី២។
- យោងតាមការចាំបាច់របស់ ក្រសួងអប់រំ យុវជន និងកីឡា។

សម្រេច

ប្រការ ១- មណ្ឌលប្រឡងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ ត្រូវកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា រៀងរាល់ឆ្នាំសិក្សា។

ប្រការ ២- ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង និងនាយកគ្រឹះស្ថានសិក្សាដែលគ្រឹះស្ថានត្រូវបានកំណត់ជាមណ្ឌលប្រឡង មានភារៈរៀបចំបន្ទប់ប្រឡង កម្រងសលាកប័ត្រឯកត្តជនរបស់បេក្ខជន បញ្ជីផ្សេងៗ និងសំភារៈចាំបាច់សម្រាប់ការប្រព្រឹត្តទៅនៃការប្រឡង ឱ្យហើយស្រេចមុនបើកសម័យប្រឡង។

ប្រការ ៣-មណ្ឌលប្រឡងនីមួយៗ ត្រូវមានប្រធាន អនុប្រធាន និងសមាជិកមេប្រយោគមួយចំនួនតាមការចាំបាច់នៃមណ្ឌលប្រឡង។

ប្រការ ៤- សមាសភាព និងចំនួនព្រមទាំងលិខិតឧទ្ទេសនាមមេប្រយោគ ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួង

អប់រំ យុវជន និងកីឡា តាមសំណើរបស់ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ។

ប្រការ ៥ - បន្ទប់ប្រឡងនីមួយៗ ត្រូវដាក់បេក្ខជនត្រឹម២៥ «ម្ភៃប្រាំ» នាក់។ បើមានបេក្ខជននៅសល់ ០៥ «ប្រាំ» នាក់ឡើងទៅ ត្រូវដាក់ក្នុងបន្ទប់មួយដោយឡែក។

ប្រការ ៦ - ប្រធានមណ្ឌលនៃមណ្ឌលសំណេរនីមួយៗ ជាអ្នកទទួលខុសត្រូវរួម ក្នុងការដំណើរការប្រព្រឹត្តទៅនៃការប្រឡងទាំងផ្នែករដ្ឋបាល ទាំងផ្នែកបច្ចេកទេសចំពោះក្រសួងអប់រំ យុវជន និងកីឡា។

ប្រការ ៧ - ប្រធានមណ្ឌល ត្រូវសហការ ឬធ្វើអន្តរាគមន៍ដល់អាជ្ញាធរមានសមត្ថកិច្ចនានាក្នុងខេត្ត-ក្រុង នៃមណ្ឌលប្រឡងក្នុងករណីចាំបាច់ ដើម្បីរក្សារបៀបរៀបរយក្នុងពេលប្រឡង។

ប្រការ ៨ - មណ្ឌល ឬអនុមណ្ឌលប្រឡងណាមួយដែលមិនមានភាពប្រក្រតីតាមលក្ខការណ៍ នៃការប្រឡង ប្រធានមណ្ឌលនៃមណ្ឌល ឬអនុមណ្ឌលនោះត្រូវរាយការណ៍ជាបន្ទាន់មក គណៈមេប្រយោគទូទាំងខេត្ត និងអាជ្ញាធរដែនដីដើម្បីដោះស្រាយ ឬសុំការសំរេចពីក្រសួងអប់រំ យុវជន និងកីឡា។

ប្រការ ៩ - ប្រធានមណ្ឌល ត្រូវបែងចែកភារកិច្ចដល់អនុប្រធាន និងសមាជិកមេប្រយោគអោយទទួលខុសត្រូវតាមមុខងាររៀងៗខ្លួន។

ប្រការ ១០-ភារកិច្ចគណៈកម្មការ អនុគណៈកម្មការ និងសមាជិកមេប្រយោគនឹងមានចែងក្នុងសេចក្តីណែនាំមួយរបស់ក្រសួងអប់រំ យុវជន និងកីឡា។

ប្រការ ១១- នឹងអនុញ្ញាតឱ្យចុះឈ្មោះប្រឡងបាន សិស្សថ្នាក់ទី៩ នៃគ្រឹះស្ថានមធ្យមសិក្សាសាធារណៈ និងឯកជន ដែលបានរៀននៅមធ្យមសិក្សាបឋមភូមិគ្រប់កំរិតថ្នាក់ និងរៀនចប់ កម្មវិធីសិក្សាថ្នាក់ទី៩ដោយគោរពបានត្រឹមត្រូវនូវបទបញ្ជាផ្ទៃក្នុងសម្រាប់គ្រឹះស្ថានមធ្យមសិក្សា ហើយត្រូវបានវាយតំលៃផ្នែកសីលធម៌រស់នៅប្រចាំឆ្នាំចាប់ពីមធ្យមឡើងទៅ។ ពាក្យសុំចុះឈ្មោះ ប្រឡងមានបិទតែម ត្រូវស្នើសុំទៅរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាតាមឋានានុក្រម។

ប្រការ ១២-អាចសុំចុះឈ្មោះប្រឡងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ ជាបេក្ខជនស្វ័យរិនបាន អតីតបេក្ខជនដែលបានប្រឡងធ្លាក់សញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ។

ប្រការ ១៣- បេក្ខជន ត្រូវភ្ជាប់នឹងពាក្យសុំប្រឡងរបស់ខ្លួននូវ ÷

- សលាកប័ត្រឯកត្តជនទំហំ១៥ស.ម គុណនឹង ២១ស.ម មានបិទរូបថតថ្មីថតចំពីមុខទំហំ៤ស.ម គុណនឹង ៦ស.ម ចំនួន ៤សន្លឹក។
- បណ្ណ័ផែបង់សិទ្ធិប្រឡង ១ច្បាប់។
- រូបថត ថតថ្មី ថតចំពីមុខ ទំហំ៤ស.ម គុណនឹង ៦ស.ម «រូបថតដែលបានបិទលើសលាកប័ត្រឯកត្តជន» ចំនួន ៣សន្លឹក។
- សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ១សន្លឹក។
- សៀវភៅសិក្ខាគារិក «ចំពោះសិស្សសាលាឯកជន»។

ប្រការ ១៤-ពាក្យសុំចុះឈ្មោះប្រឡង នឹងត្រូវប្រមូលផ្តុំតាមគ្រឹះស្ថានសិក្សាដែលខ្លួនសិក្សា។ នាយកគ្រឹះស្ថានសិក្សាត្រូវប្រមូលសំណុំលិខិតរបស់បេក្ខជន បញ្ជូនទៅមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង ដើម្បីធ្វើការបែងចែកនាមត្រកូលបេក្ខជនតាមលំដាប់អក្សរក្រម (លំដាប់ ព្យញ្ជនៈ និង ស្រៈ) ទៅតាមបន្ទប់ប្រឡង។

ប្រការ ១៥-បេក្ខជនស្វ័យរិន ត្រូវដាក់ពាក្យសុំប្រឡង ដោយមានបញ្ជាក់សម័យប្រឡង មណ្ឌលប្រឡង

លេខបន្ទប់ លេខតុ នៃសម័យប្រឡងមុន នៅតាមមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុងដែលសាមីខ្លួនបានសុំប្រឡងពីមុន។ បើមានបំណងចង់ប្រឡងនៅខេត្ត-ក្រុងថ្មីដែលខ្លួនបានប្តូរលំនៅដ្ឋាននោះត្រូវ មានសេចក្តីបញ្ជាក់លើពាក្យសុំប្រឡងពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុងដែលសាមីខ្លួនបានប្រឡងធ្លាក់ពីមុន។

